Formation, Dialogue, Cooperation

# អ្នកនាំសារ The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣០ ខែតុលា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៩១




អេម៉ាណូអែល
"សម្លេងផ្សាយពីព្រះសហគមន៍កាតូលិក"

| | | |
|---|---|---|
| ភ្នំពេញ | : FM 104 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| បាត់ដំបង | : FM 91.0 Mhz | ម៉ោង ៧:៣០- ៨:៣០ យប់ |
| សៀមរាប | : FM 107.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| កំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 92.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |



# រូបថតសកម្មភាពផ្សេងៗ



កាលពីដើមខែវិច្ឆិកានេះ រដ្ឋាភិបាលកម្ពុជាបានដកសិទ្ធិរបស់ក្រុមសុខាអូតែលរបស់លោកឧញ៉ា សុខ គង់ ដែលមានសិទ្ធិលក់សំបុត្រចូលទស្សនាតំបន់អង្គរនៅខេត្តសៀមរាប។ ក្រោយពីការដកហូតនេះ រដ្ឋាភិបាលកំពុងតែរៀបចំបង្កើតសហគ្រាសសាធារណៈមួយដែលគ្រប់គ្រងដោយរដ្ឋាភិបាល។



យុវជនស៊ីកនីសអាស៊ី ( Signis Asia ) ចុះកម្មសិក្សានៅសារៈមន្ទីរជាតិទួលស្លែង



ប្រជាពលរដ្ឋប្រមាណជាង២០០នាក់ធ្វើបាតុកម្មទំលាក់លោកកឹម សុខាពីតំណែងអនុប្រធានរដ្ឋសភាទី១។






យុវជនស្វះស្វែងរកការងារនិងយល់ដឹងអំពីស្ថាប័នការងារនានាក្នុងប្រទេសតាមរយៈពិពណ៌ការងារដែលរៀបចំដោយទីភ្នាក់ងារជាតិមុខរបរនិងការងារ ( NEA )។

CSC
Formation, Dialogue, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ចូររៀបចំផ្លូវថ្វាយព្រះអម្ចាស់ !



*លោក លី សុវណ្ណា*
*ចាងហ្វាងកាសែតអ្នកនាំសារ*

តាមប្រតិទិន នៃព្រះសហគមន៍កាតូលិក យើងបានឈានចូលឆ្នាំថ្មីមួយទៀតហើយ។ ពេលនេះជាពេលវេលាដែលគ្រីស្តបរិស័ទ ត្រូវរៀបចំចិត្តគំនិតដើម្បីទទួលព្រះអម្ចាស់ ដែលយាងមកយកកំណើតជាមនុស្ស គឺជាព្រះយេស៊ូកុមារ។ ព្រះយេស៊ូបានប្រសូតមកជាមនុស្សជាង២០០០ឆ្នាំមកហើយ តើយើងទទួល ព្រះយេស៊ូយាងមករបៀបណា? ព្រះយេស៊ូប្រសូតម្តងទៀត ឬយ៉ាងណា? មិនមែនទេព្រះយេស៊ូប្រសូតតែម្តងជាស្រេច។

ព្រះសហគមន៍កាតូលិកបានចែងឲ្យមានជារដូវបុណ្យផ្សេងៗ នាំឲ្យគ្រីស្តបរិស័ទរិះគិត និងផ្ទង់ស្មារតីជានិច្ចកុំឲ្យរវាទចិត្ត សប្បាយរីករាយភ្លេចខ្លួននោះឡើយ។ ដោយសារ ព្រះជាម្ចាស់ស្រឡាញ់មនុស្ស ហួសពីការស្មានរបស់មនុស្ស គឺព្រះយេស៊ូជាព្រះអម្ចាស់បានប្រសូតជាមនុស្ស និងបានបូជាព្រះជន្មផ្ទាល់របស់ព្រះអង្គ ព្រោះតែអំពើបាបរបស់មនុស្ស និងដើម្បីរំដោះមនុស្សឲ្យបានរួចពីបាប។

មកដល់កន្លែងនេះ អ្នកនាំសារសូមនាំអារម្មណ៍បងប្អូន ឲ្យរិះគិតខ្លះនូវព្រឹត្តិការណ៍ថ្មីៗ ដែលបានកើតឡើងក្នុងពិភពលោក និងនៅកម្ពុជា។

នយោបាយនៅកម្ពុជា បានឡើងកំដៅយ៉ាងខ្លាំងមួយរយៈចុងក្រោយនេះ ព្រោះតែប្រៀបធៀបលទ្ធផល នៃការបោះឆ្នោតនៅប្រទេសមីយ៉ាន់ម៉ា ដែលគណបក្សប្រឆាំង ទទួលបានជោគជ័យក្នុងការបោះឆ្នោត ហើយកម្ពុជាក៏នឹងដើរលើផ្លូវនេះដែរ។ព្រមទាំងមានករណីជាច្រើនទៀត ដែលគណបក្សប្រឆាំងនៅកម្ពុជា បានរិះគិតមិនសំចៃមាត់មកលើរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលក៏បានចាត់ការតបវិញធ្ងន់គួរសមដែរ ។ តុលាការបានចេញដីកា ឲ្យចាប់ខ្លួនមេបក្សប្រឆាំង ទាក់ទងនឹងរឿងបរិហាកេរ្តិ៍តាមបណ្តឹង របស់លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង។ ព្រមទាំងមានដីកាមួយទៀត ឲ្យមេបក្សចូលបំភ្លឺអំពីការផ្សាយឯកសារក្លែងក្លាយ ។ ករណីទាំងប៉ុន្មាន នាំឲ្យមេបក្សប្រឆាំងផ្អាកដំណើររបស់ខ្លួន វិលមកប្រទេសកម្ពុជាវិញ។

កម្ពុជាមានពិសោធន៍ ក្នុងការដោះស្រាយបញ្ហា ដែលបានកើតឡើងនៅកម្ពុជា មេដឹកនាំទាំងពីរបានប្រកាសរួចហើយថា មានតែខ្មែរទេដែលអាចដោះស្រាយបញ្ហារបស់ខ្មែរបាន។ជាការពិតណាស់ អ្នកដទៃ គ្រាន់តែជាអ្នកសង្កេតការប៉ុណ្ណោះ ស្ថានភាពជាក់ស្តែងមានតែខ្មែរខ្លួនឯង ជាអ្នកដឹងច្បាស់។ យើងគាំទ្រជានិច្ច នូវវប្បធម៌សន្ទនាដែលមេដឹកនាំទាំងពីរសន្យាបន្ត បើទោះបីអ្នកវិភាគជាច្រើនបាននិយាយថា វប្បធម៌នេះបានស្លាប់ទៅហើយក្តី។

ការស្រុះស្រួលផ្ទៃ គឺជាកត្តាប្រសើរបំផុតក្នុងការរក្សាសន្តិភាព និងភាពសុខដុមរមនា ព្រមទាំងការអភិវឌ្ឍរីកចម្រើនសម្រាប់កម្ពុជាបាន។ បើយើងក្រឡេកមើលទិដ្ឋភាព នៅមជ្ឈិមបូព៌ាបានបញ្ជាក់យ៉ាងច្បាស់ថា ការបាក់បែកផ្ទៃក្នុង ការជ្រៀតជ្រែកពីបណ្តាមហាអំណាច ដែលជនមួយចំនួនបានគិតថាគេជួយដើម្បីនាំឲ្យប្រទេស មានលទ្ធិប្រជាធិបតេយ្យ មិនច្បាស់លាស់នោះបាន និងកំពុងធ្លាក់ក្នុងសង្គ្រាមបង្ហូរឈាមជារៀងរាល់ថ្ងៃ។ អង្គការរដ្ឋឥស្លាមបានចេញខ្លួន មកប្រឆាំងលោកខាងលិច នាំឲ្យពិភពលោកមានការជ្រួលច្របល់ នោះក៏សាហាវយង់ឃ្នងសម្លាប់រង្គាលគ្មានមេត្តាឡើយ។ ទាំងលោកខាងលិច ដែលមនុស្សគ្រប់គ្នាថា ជាបិតាប្រជាធិបតេយ្យ ទាំងមហាអំណាចរុស្ស៊ី ទាំងពួករដ្ឋឥស្លាម មួយណាសាហាវពិតប្រាកដ? អ្នករងវេទនា គឺប្រជាជនស្លូតត្រង់ កុមារតូចដែលមិនដឹងអី។ បង្កឲ្យមានជនភៀសខ្លួនរាប់មិនអស់ មនុស្សស្លាប់ និងរបួសរាល់ថ្ងៃ។

សរុបមក ការស្រុះស្រួលគ្នា ការយល់ដឹងពីគ្នា ការសន្ទនា ការស្តាប់គ្នា ការឯកភាពផ្ទៃក្នុង នៃជាតិសាសន៍នីមួយៗ វាសំខាន់ណាស់ ក្នុងការរក្សាសុខសន្តិភាព ការអភិវឌ្ឍ និងភាពរុងរឿងជូនពលរដ្ឋរបស់ខ្លួនយ៉ាងពិតប្រាកដ។

សូមឲ្យម្នាក់ៗ បាននឹកដល់ជនទាំងឡាយ ដែលរងទុក្ខដោយសារសង្គ្រាម ដោយសារការចាប់ជំរិត ដោយការបាញ់ប្រហារសម្លាប់រង្គាល នៅក្នុងការរៀបចំចិត្តគំនិត រៀបចំផ្លូវទទួលព្រះអម្ចាស់ដែលយាងមក។ សូមអធិដ្ឋានសម្រាប់អ្នកណែនាំ អ្នកដឹកនាំឲ្យគិតដល់ប្រជាជនជាធំ ដោយឥតគិតប្រយោជន៍ និងអំណាចផ្ទាល់ខ្លួន។ សូមព្រះអង្គប្រទានពរ ដល់អ្នកដឹកនាំទាំងអស់ ដែលស្រឡាញ់សន្តិភាពពិតប្រាកដ៕


Radio Veritas Asia
Khmer Service
"សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា"

វិទ្យុវ៉ារីតាស់អាស៊ី (RVA Khmer Service) ផ្សាយតាមរលកធាតុអាកាសខ្លី (SW) ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :
ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

វិទ្យុវ៉ារីតាស់អាស៊ី ២៤ម៉ោង តាមប្រព័ន្ធអ៊ីនធឺណែត លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ីភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬ ប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Downloadកម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។



ស្តាប់វិទ្យុវ៉ារីតាស់អាស៊ី (RVA Khmer Service) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។



វិទ្យុវ៉ារីតាស់អាស៊ី (RVA Khmer Service)
ផ្សាយតាមវិទ្យុ(FM)ជាភាសាខ្មែររយៈពេល៥០នាទីរាល់ថ្ងៃ :

ភ្នំពេញ : FM 104 Mhz ម៉ោង ៥:០០- ៦:០០ រសៀល
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០- ៨:៣០ យប់
កំពង់ធំ : FM 103.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
សៀមរាប : FM 107.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៧:០០- ៨:០០ យប់
ព្រះសីហនុ : FM 92.5 Mhz ម៉ោង ៥:០០- ៦:០០ រសៀល
កំពត : FM 93.25 Mhz ម៉ោង ៥:០០- ៦:០០ រសៀល

www.catholiccambodia.org
web: khmer.rveritas-asia.org

# កន្ទុយលេខ៖ អ្នកលេងថា ជារឿងតិចតួច ប៉ុន្តែអ្នកមិនលេងថា អាជ្ញាធរគួរមានវិធានការ



*ស្ត្រីវៀតណាមដើរលក់ឆ្នោតនៅតាមហាងកាហ្វេនាទីក្រុងភ្នំពេញ។រូបភាពៈcsc*

កន្ទុយលេខនៅក្នុងប្រទេស នៅពេលនេះ គឺហាក់បីដូចជា កំពុងតែកើតមានពេញបន្ទុកនៅទូទាំងប្រទេស ប៉ុន្តែអាជ្ញាធរហាក់ដូចជា ព្រងើយកន្តើយលើបញ្ហានេះ ទោះបីជាកន្លងមក វាត្រូវបានប្រមុខរដ្ឋាភិបាលកម្ពុជា ចាត់ទុកថា គឺជាសកម្មភាពខុសច្បាប់ ។

នៅក្នុងស្រទាប់មហាជន នៅពេលនេះ កន្ទុយលេខ សឹងតែក្លាយទៅជាល្បែងស៊ីសងមួយ ដែលមានលក្ខណៈជាប្រពៃណីទៅហើយ ដោយអ្នកខ្លះចាក់រាល់ថ្ងៃ អ្នកខ្លះចាក់ នៅពេលជួបហេតុការណ៍ចម្លែក នៅក្នុងសង្គមផ្ទាល់ខ្លួន... ។ល។

លោក សុវណ្ណ ឌួង ជាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលមួយ បានមានប្រសាសន៍ថា បច្ចុប្បន្ននេះ កន្ទុយលេខនេះមានគ្រប់កន្លែង មិនថានៅទីក្រុង ទីរួមខេត្ត តំបន់ទីប្រជុំជន ផ្សារ ឬ តាមភូមិនោះទេ គឺមានគ្រប់ច្រកល្ហកហើយមានខ្លះ គេចាក់ពេលព្រឹក ពេលថ្ងៃ ពេលយប់ក៏មានដែរ ។

លោកបានបញ្ជាក់ថា "ខ្ញុំឃើញគ្រប់កន្លែង រហូតដល់កន្លែងខ្លះ ខ្ញុំធ្លាប់ជួបគេជិះម៉ូតូដើរប្រមូលតាមផ្ទះ តាមភូមិថែមទៀតផង"។

លោកបានបន្តទៀតថា តាមការសង្កេតរបស់លោកផ្ទាល់ នៅពេលដែលចុះទៅបំពេញការងារ នៅតាមមូលដ្ឋាននៅក្នុងតំបន់ដែនសកម្មភាព នៃគម្រោងការងាររបស់លោក នៅពេលនេះ នៅតាមស្រុកតាមភូមិ គេមិនហៅថា កន្ទុយលេខនោះទេ គឺគេហៅល្បែងស៊ីសងប្រភេទនេះថា គឺជាការលេងឆ្នោត ហើយអ្នកខ្លះ លេងជារៀងរាល់ថ្ងៃ។

លោកបានបញ្ជាក់ថា "អ្នកញៀនមែនទែន សូម្បីតែលេខម៉ូតូ ដែលខ្ញុំជិះចុះទៅតាមភូមិជួបពួកគាត់ គាត់សុំយកលេខទៅចាក់ ហើយអ្នកខ្លះ ដាច់ចិត្តដល់ទៅទូរស័ព្ទមកខ្ញុំ សួរអាយុនៅពេលគាត់យល់សប្តិ ឃើញពាក់ព័ន្ធនឹងខ្ញុំយកទៅកាត់ចាក់"។

ជុំវិញបញ្ហានេះ លោកស្រី ចេង សេដា ជាអ្នកជំនួញដួញដូង ហើយក៏ជាអ្នកញៀននឹងការលេងកន្ទុយលេខនេះមួយរូបបានអះអាងថា នៅក្នុងមួយថ្ងៃ លោកស្រី តែងចំណាយចាក់កន្ទុយលេខនេះ ប្រហែលជា ១.០០០ ទៅ២.០០០រៀលអីទេ ដោយពិពណ៌នាការចំណាយនេះថា គឺជាការកំសាន្តមួយ ឬក៏ជាការផ្សងសំណាងមួយប្រចាំថ្ងៃ ។

លោកស្រីបានបញ្ជាក់ថា "១.០០០ ទៅ ២.០០០ រៀល បើខុសមេស៊ីអស់ក៏អស់ទៅ វាដូចជាការចំណាយ ដែលប្រុសៗគេទិញបារីជក់ចឹងទៅ តែថ្ងៃណាមានហុងស៊ុយត្រូវក៏មាន "។

លោកស្រីបានបន្តថា ក្រៅពីរកស៊ីហាត់នឿយ ចេះតែចំណាយបន្តិចបន្តួចដើម្បីផ្សងសំណាងនឹងគេទៅ ដោយនៅក្នុង ១.០០០ បើចាក់ពីរលេខគេសង ៧០.០០០ តែបើហេងចាក់បីលេខត្រូវ គឺគេសងដល់ទៅ ៦០០.០០០ ពោល គឺ១សងពី ៧០ ទៅ ៦០០ ដង។ ប៉ុន្តែពេលចាក់ មេគេកាត់ទឹក ដោយកន្លែងខ្លះ ពី២០០ ទៅ ២៥០ រៀលទៅ ៣០០ រៀល ក៏មានតាមកន្លែង ។

ដោយសារតែកំណើន នៃចំនួនអ្នកលេងច្រើន អ្នកដែលជាមេនេះ ក៏រីកដុះដាលច្រើនដែរ ហើយម្នាក់ៗ ខិតខំបំពេញសេវាកម្ម ដើម្បីទំនុកចិត្តអតិថិជនរបស់ខ្លួន ។

ស្ត្រីអ្នកប្រកបរបរ ធ្វើមេកន្ទុយលេខមួយរូប ដែលសុំមិនបញ្ចេញឈ្មោះ គឺបានឲ្យដឹងថា នៅក្នុងមួយថ្ងៃ គាត់អាចទទួលអតិថិជនប្រមាណជា ១០០ ទៅ២០០នាក់ក៏មាន ហើយគិតសរុបទៅ អាចប្រមូលបាន ពី ១ លានទៅ ៣ លាននៅក្នុងមួយថ្ងៃ។

តាមការរៀបរាប់របស់បងស្រី គាត់មិនមែនជាមេធំនោះទេ គឺមានមេផ្សេងទៀត ពោលគឺបន្ទាប់ពីប្រមូលបាន គឺយកទៅឲ្យមេមួយទៀតតាមវីង "wing" ហើយមេនេះទៀតសោត គឺជួនកាលយកទៅឲ្យមេធំៗ ខាងលើថែមទៀត ហើយជាទូទៅ គឺស៊ីសងគ្នាតាមវីង "wing" ហើយបើមានអ្នកត្រូវ មេក៏ផ្ញើលុយតាមវីង "wing"នេះ ហើយខ្ញុំក៏បើកយកទៅឲ្យអ្នកដែលចាក់ត្រូវ ហើយគេសប្បាយចិត្ត ខ្លះហុច ១០.០០០ ២០.០០០តាមហ្នឹងទៀតទៅ ។

ជាមួយនឹងកិច្ចការទាំងនេះ នៅក្នុងមួយថ្ងៃ អ្នកស្រីអាចរកចំណូលបាន ប្រមាណជា ៤ ទៅ ៥ម៉ឺនរៀលដែរនៅក្នុងមួយថ្ងៃដើម្បីចិញ្ចឹមជីវិត។

ជុំវិញបញ្ហាកន្ទុយលេខនេះ លោក ឌួង បានមានប្រសាសន៍ថា អាជ្ញាធរគួរតែមានវិធានការណ៍ ពីព្រោះឥឡូវនេះវាច្រើនណាស់ ហើយអ្នកចាក់ខ្លះតាមដឹង មិនមែនលេង ១.០០០ទៅ ២.០០០រៀលទេ គឺរាប់ម៉ឺនក៏មានដែរ ។

លោកបានបញ្ជាក់ថា "អ្នកខ្លះចាក់ដល់ទៅរាប់ម៉ឺន នៅពេលគាត់ប្រាកដថា យល់សប្តិ៍ច្បាស់ តែមានអី មេស៊ីអស់ៗ ហើយបើត្រូវវិញ គឺមានតែ ១.០០០ទៅ ២.០០០រៀលនេះឯង"។

លោកបានបន្តទៀតថា ១.០០០ ទៅ ២.០០០រៀល ជារឿងតិចទេ ប៉ុន្តែបើសិនជាគាត់សន្សំទុក រាប់សិបរាប់ថ្ងៃទី គាត់សល់លុយនៅក្នុងដៃ ប៉ុន្មានចុះបើចាក់រាល់តែថ្ងៃ ហើយយូៗ ត្រូវម្តង វាមិនអាចសមាមាត្រគ្នាបានទេ ។

លោក ចេង ហួតលាង ជាប្រជាពលរដ្ឋមួយរូបនៅផ្សារកណ្តាល បានឲ្យដឹងថា រហូតមកដល់ពេលនេះ ក្រៅពីកន្ទុយលេខនេះចេញ នៅកម្ពុជានៅមានបាតុភាពមួយទៀត ដែលគួរតែយកចិត្តទុកដាក់ដែរគឺឆ្នោតវៀតណាម។

លោកបានបន្តថា បញ្ហាឆ្នោតវៀតណាមនេះ គឺមិនត្រឹមតែ ជាអក្សរវៀតណាមទេ មកលក់នៅស្រុកខ្មែរ សូម្បីតែអ្នកលក់នោះ ក៏ជាស្ត្រី វៀតណាម ដែលអ្នកខ្លះមិនចេះទាំងនិយាយភាសាខ្មែរផង ដើរលក់ឆ្នោតនៅតាមផ្សារ តាមហាងកាហ្វេ៕

*ដោយអរិយបុត្រ*

# យុវជនចង់ឲ្យមេដឹកនាំគណបក្សពីរមានអាសនៈនៅសភារួមគ្នា ពង្រឹងគុណភាពអប់រំ

បណ្តាយុវជន ដែលកំពុងតែ ទទួលការបណ្តុះបណ្តាល និងអប់រំនៅក្នុងប្រទេស បានស្នើឲ្យគណបក្សនយោបាយ ដែលមានអាសនៈ នៅក្នុងសភាទាំងពីរិះគិតរួមគ្នា ដើម្បីពង្រឹងគុណភាពទាំងអស់គ្នា ។

ថ្មីៗនេះ បញ្ហាគុណភាពនៃការអប់រំនៅក្នុងប្រទេសបានក្លាយជាប្រធានបទដ៏ក្តៅមួយ រវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ដែលធ្វើគណបក្សទាំងពីរ បានធ្វើការរិះគន់គ្នាទៅវិញទៅមក ដោយការរិះគន់នេះ គឺបានធ្វើទាំងតាម បណ្តាញទំនាក់ទំនងសង្គម រហូតដល់ធ្វើតាមរយៈ សុន្ទរកថាថែមទៀតផង ។

ជុំវិញការរិះគន់ និងថ្លែងសារនយោបាយទៅវិញទៅមក រវាងគណបក្សនយោបាយធំៗ នៅកម្ពុជាទាំងពីរ យុវជន ដែលកំពុងតែសិក្សានៅកម្ពុជាមួយចំនួន បានសុំឲ្យប្រមុខគណបក្ស និង សមាជិកបក្សទាំងពីរ រួមគ្នាដោះស្រាយបញ្ហានេះ ។

លោក រុន រ័ត្ន ជានិស្សិតឆ្នាំ ទី៤ មួយរូប បាននិយាយថា សារនយោបាយវាមិនមែនជារឿងសំខាន់ សម្រាប់ដោះស្រាយបញ្ហាគុណភាពអប់រំបានទេ ។ លោកបានបន្តថា សារនយោបាយដែលថ្លែងដោយ ប្រមុខគណបក្សនយោបាយទាំងពីរ កន្លងមកគ្រាន់តែជាការបង្ហាញនូវបញ្ហាតែប៉ុណ្ណោះ ប៉ុន្តែមិនបានបង្ហាញអំពីដំណោះស្រាយ ឬ ក៏យុទ្ធវិធី ឬ ក៏ផែនការ ដើម្បីពង្រឹងគុណភាពនៃវិស័យអប់រំនេះនៅឡើយ។

លោកបានបញ្ជាក់ថា "បើថ្លែងទៅថ្លែងមក គឺគុណភាពអប់រំនៅតែដដែល ប៉ុន្តែ បើអង្គុយចុះ ហើយពិភាក្សារួមគ្នារកវិធីពង្រឹងគុណភាព នោះប្រហែលជាអ្នកជំនាន់ក្រោយដូចពួកខ្ញុំអាចនឹងមានឱកាសស្គាល់គុណភាព នៃការអប់រំមួយពិតប្រាកដ"។

លោកបានបញ្ជាក់ទៀតថា "បើគណបក្សមួយ រកឃើញបញ្ហាអវិជ្ជមាន ហើយមួយទៀតជាអ្នកអនុវត្ត ធ្វើការទាំងអស់គ្នា នោះបញ្ហានឹងត្រូវដោះស្រាយ"។

កញ្ញា ច័ន្ទ សុប្ញស្ស ជាយុវនិស្សិតឆ្នាំទី ៣ ផ្នែកគណនេយ្យមួយរូប បានឲ្យដឹងថា គុណភាពសញ្ញាបត្រអប់រំក្នុងស្រុក នៅតែជាប្រធានបទមួយ ដែលមេដឹកនាំរដ្ឋាភិបាល និងមេបក្សប្រឆាំងលើកយកមករិះគន់ គ្នាទៅវិញទៅមកជាពិសេសនៅពេលថ្មីៗនេះ។

កញ្ញា បានបន្តទៀតថា ប្រហែលជាកន្លះខែនេះ នៅតាមបណ្តាញទំនាក់ទំនងសង្គម ដូចជាហ្វេសបុកអី តាមកាសែត តាមទូរទស្សន៍ តាមវិទ្យុ គឺមានព័ត៌មានច្រើន ដែលនិយាយអំពីបញ្ហាគុណភាពនៃការអប់រំនេះ។

ទាក់ទិននឹងបញ្ហានេះ កញ្ញា សុប្ញស្ស ដែលកំពុងតែសិក្សាផ្ទាល់ បានអះអាងថា បើនិយាយអំពីគុណភាព និងបរិយាកាសកន្លែងរៀន សម្ភារសិក្សានៅក្នុងប្រទេស ប្រហែលជាមិនទាន់អាចប្រៀបធៀប ជាមួយនឹងប្រទេសផ្សេងៗទៀតបានទេ ប៉ុន្តែបើនិយាយអំពីសមត្ថភាពនិស្សិត ប្រហែលជាមិនអន់ជាងគេប៉ុន្មានទេ រឿងជំនាញ។ អ្វីដែលយើង កំពុងតែប្រឈមនៅពេលនេះ គឺអាចប្រហែលជាបញ្ហាភាសា។

កញ្ញាបានបញ្ជាក់ថា "បើគណបក្សទាំងពីរអាចរិះគិតគ្នារកមធ្យោបាយផ្តល់ឲ្យនិស្សិតយើង នូវការបណ្តុះបណ្តាលភាសានេះឲ្យច្រើនជាងនេះ ប្រហែលជាប្រសើរ"។

កាលពីពេលថ្មីៗនេះ លោក សម រង្ស៊ី ដែលជាប្រធានគណបក្សសង្គ្រោះជាតិ និងជាអ្នកនយោបាយ ដែលគេដឹងថា បានទទួលការបណ្តុះបណ្តាលនៅប្រទេសបារាំង បាននិយាយរិះគន់ដល់គុណភាព នៃការអប់រំនៅកម្ពុជា ហើយបានដាក់សំណួរទៅលើការទទួលស្គាល់សញ្ញាបត្រនៅក្នុងស្រុក ។

ឆ្លើយតបនឹងការរិះគន់នេះ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានរិះគន់តបមកវិញ ដោយអះអាងថា នេះគឺជាការប្រមាថមួយ ។

ជុំវិញការរិះគន់របស់លោក សម រង្ស៊ី សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង ជាប្រធានគណបក្សប្រជាជនកម្ពុជា បានថ្លែងវាយបកវិញ ទាំងតាមបណ្តាញទំនាក់ទំនងសង្គម និងតាមសុន្ទរកថា ផ្ទាល់ថា ការនិយាយថា សញ្ញាបត្រអប់រំក្នុងស្រុកអត់តម្លៃនោះ ថាជាការប្រមាថមួយដល់ស្ថាប័នអប់រំរបស់ជាតិ និងអ្នកដែលកំពុងធ្វើការក្នុងស្ថាប័នផ្សេងៗ រាប់ទាំងអ្នកដែលកំពុងធ្វើការបម្រើឲ្យបក្សប្រឆាំង ដែលភាគច្រើន គឺសុទ្ធតែជាអ្នកដែលគ្មានសញ្ញាបត្រពីបរទេស ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍បញ្ជាក់ថា "តើបណ្ឌិតប៉ុន្មាននាក់ទៅ ដែលមកពីក្រៅប្រទេស ហើយតើមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងអ្នកធ្វើការក្នុងប្រទេស គ្រូបង្រៀនជាង ១១ម៉ឺននាក់ ប៉ុន្មាននាក់ទៅ ដែលបានរៀននៅក្រៅប្រទេស គឺសុទ្ធតែគ្រូ និងសាស្ត្រាចារ្យអត់មានតម្លៃទាំងអស់ នេះជាការប្រមាថធ្ងន់បំផុតទៅលើស្ថាប័នអប់រំ ទៅលើអតីតសិស្សនិស្សិត ដែលបានរៀនក្រោយឆ្នាំ១៩៧៩ និងអ្នកទទួលបានសញ្ញាបត្រនៅថ្ងៃនេះទាំងអស់ គឺសុទ្ធតែពួកអត់តម្លៃឬ "៕

*ដោយអរិយបុត្រ*



*យុវជនចេញពីប្រឡងសញ្ញាបត្រទុតិយភូមិកាលពីឆ្នាំ២០១៥កន្លងទៅ។រូបថតៈ ស្រីម៉ាច*

# ព្រះសហគមន៍កាតូលិកនៅកម្ពុជា រៀបចំមហាសន្និបាត គ្រូអប់រំជំនឿបីភូមិភាគ



*រូបថតអនុស្សាវរីយ៍សន្និបាទគ្រូអប់រំជំនឿទាំងបីភូមិភាគ។*

គ្រូអប់រំជំនឿ នៅក្នុងព្រះសហគមន៍កាតូលិកកម្ពុជាទាំងបីភូមិភាគ កាលពីចុងខែតុលា កន្លងទៅនេះ បានជួបជុំគ្នានៅព្រះវិហារសន្តប៉ូល និង សន្តសិលាឬមណ្ឌលសកម្មភាពភ្នំពេញថ្មី រយៈពេលបីថ្ងៃ នៅក្នុងសន្និបាតរួមគ្នាមួយ ក្រោមអធិបតីភាពរបស់លោកអភិបាល នៃព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។

នៅក្រោមការណែនាំ ដោយលោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ឝ្មីតអឺស្លែ, អភិបាលភូមិភាគបាត់ដំបង អេនរីគេ ហ្វីការេដូ និងលោកអភិបាលនៃភូមិភាគកំពង់ចាម អន់តូនីសាមីស៊ូសែរាជ្យ ពីថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៥ បណ្ដាគ្រូអប់រំជំនឿទាំងអស់ ដែលបានរួមគ្នារិះគិត អំពីពិធីផ្សេងៗ ដើម្បីជួយពង្រឹង និងបង្កើនជំនឿដល់អ្នកដែលមកទទួលការអប់រំ ។

ក្នុងថ្ងៃដំបូង នៃកម្មវិធីលោកអភិបាលនៃព្រះសហគមន៍កាតូលិក ភូមិភាគកំពង់ចាម បានពន្យល់អំពីពិធីតូចៗជាពន្លឺ និងជាប្រភពនៃជីវិត ដោយលើកឡើងថា ៖ ពិធីនានាដែលយើងបានប្រារព្ធក្នុងអភិបូជា មានទឹកប្រេង ផេះ ភ្លើង និង ទាន គំនូរ ចម្លាក់រចនាក៏ដូចជា អាគារជាដើម គឺបានមកពីគ្រីស្តបរិស័ទ ដែលបានខិតខំរៀនសូត្រ និងធ្វើអស់ពីកម្លាំងកាយចិត្តដើម្បីថ្វាយទៅព្រះជាម្ចាស់។

នាថ្ងៃបន្ទាប់ ក្រុមព្រះសហគមន៍ភូមិភាគបាត់ដំបង បានជួយដល់អង្គសន្និបាតឲ្យរឹតតែយល់បន្ថែម ពីពិធីផ្សេងៗ ដែលជួយ បញ្ជ្រាបជំនឿរបស់ព្រះសហគមន៍ ដល់អ្នកដែលស្វែងរកជំនឿ និងយល់ពីគោលបំណង នៃការធ្វើពិធីទាំងនោះ ដើម្បីជួយឱ្យស្រឡាញ់ពិធីបុណ្យ ជួយឱ្យចូលរួមយ៉ាងសកម្មក្នុងពិធីបុណ្យ ហើយអាចជួយពន្យល់ដល់សិស្ស អ្នកភូមិ និងអ្នកដែលចង់ស្វែងយល់ អំពីពិធីបុណ្យរបស់ព្រះសហគម៍នានា។

លោក អេនរីគេ ហ្វីការេដូ បានមានប្រសាសន៍ថា អង្គសន្និបាតនេះក៏ជាឱកាសមួយដើម្បីផ្ដល់នូវ ការពន្យលពីសារៈសំខាន់នៃពិធី និង សកម្មភាពផ្សេងៗ ក្នុងការចិញ្ចឹមជំនឿ ដោយជួយឱ្យអ្នកទទួលការអប់រំ មានកម្លាំងកាយ និង វិញ្ញាណបន្តដំណើរទៅមុខ។

លោកបានបន្តថា នេះគឺជាកម្មវិធីដែលជួយឲ្យអ្នកទទួលការអប់រំ កាន់តែមានភាពជិតស្និទ្ធិជាមួយព្រះសហគមន៍ជួយ ពង្រឹងជំនឿអ្នកដែលមកទទួលការអប់រំឲ្យកាន់តែរឹងមាំឡើង និងលើកទឹកចិត្តឲ្យអ្នកទទួលការអប់រំ ឲ្យរស់នៅជិទស្និទ្ធិជាមួយព្រះយេស៊ូ តាមរបៀបអធិដ្ឋានរិះគិតអំពីព្រះបន្ទូល និងសម្ដែងធម៌មេត្តាករុណាជាដើម។

លោកបានបញ្ជាក់ថា "សរុបសេចក្ដីមក គឺជួយឲ្យគ្រូអប់រំជំនឿ អាចមានសមត្ថភាពបញ្ជ្រាប នូវអត្ថន័យនៃជីវិតប្រចាំថ្ងៃទៅនឹងព្រះសហគមន៍ និងព្រះជាម្ចាស់"។

នៅក្នុងឱកាសនោះដែរ លោកអភិបាលភូមិភាគភ្នំពេញ បានចូលរួមចែករំលែក អំពីរបៀបនៃការរៀបចំពិធីបុណ្យ និងគោលបំណង នៃអ្នកស្វែងរកជំនឿ ជាមួយនឹងគ្រូអប់រំជំនឿទាំងអស់ ។

លោកបានមានប្រសាសន៍ថា តួនាទីនៃអ្នកណែនាំជំនឿ គឺជាអ្នកដែលផ្ដល់សក្ខីភាពខាងជំនឿ និងលើកទឹកចិត្តឲ្យអ្នកដែលស្វែងយល់យកព្រះបន្ទូល និងព្រះយេស៊ូជាទីពឹង៕

# លោកអភិបាលអំពាវនាវសុំជំនួយដើម្បីសង់ព្រះវិហារអរិយក្សត្រ

លោកអភិបាលអូលីវីយេ ឝ្មីតអឺស្លែរ បានមានប្រសាសន៍ថា លោកមានគម្រោងនឹងរើទីតាំង ព្រះវិហារព្រះមាតានៃសន្តិភាព របស់ព្រះសហគមន៍អរិយក្សត្រ ដែលស្ថិតនៅលើកូនកោះនៅទល់មុខទន្លេចតុមុខ នារាជធានីភ្នំពេញ ទៅកន្លែងផ្សេងទៀត នៃតំបន់អរិយក្សត្រដដែលនេះ។

លោកអភិបាល មានប្រសាសន៍ដូច្នេះកាលពីថ្ងៃទី១៥ វិច្ឆិកា ដែលជាខួបនៃការស្រង់រូបព្រះនាងម៉ារី ពីទន្លេមេគង្គ ដែលមានគ្រីស្តបរិស័ទ ចូលរួមជាង១០០០នាក់។

ព្រះវិហារព្រះមាតានៃសន្តិភាព នៃព្រះសហគមន៍អរិយក្សត្រ អាចទទួលមនុស្ស ឲ្យអង្គុយខាងក្នុងវិហារបានចំនួន ប្រមាណតែជាង ២០០នាក់ប៉ុណ្ណោះ ហើយរាល់ពេលដែលមានកម្មវិធីបុណ្យម្ដងៗ គ្រីស្តបរិស័ទត្រូវឈរ និងអង្គុយនៅខាងក្រៅបរិវេណព្រះវិហារ។ លោកអភិបាល មានប្រសាសន៍ថា "ខ្ញុំបានឃើញថាព្រះវិហារនេះចង្អៀតមែនទែន។ ហើយបើតាមខ្ញុំគិត ទីកន្លែងនៅក្បែរវាំងផង និងទីក្រុងភ្នំពេញ ចង់អភិវឌ្ឍន៍ និងរីកចម្រើនផង ដូច្នេះខ្ញុំព្រួយបារម្ភអំពីទីកន្លែងរបស់យើង"។

លោកអភិបាលបន្ថែមថា ទីតាំងព្រះវិហារថ្មី សម្រាប់ព្រះសហគមន៍អរិយក្សត្រនេះ នឹងមានចម្ងាយប្រមាណ ៣ ឬ៤គីឡូម៉ែត្រពីទីតាំងចាស់ ហើយនឹង មានកន្លែងទូលាយជាងនេះ ដើម្បីធ្វើជាកន្លែងសម្រាប់អន្តរភូមិភាគ ។ លោកអភិបាល "ខ្ញុំនឹងរៀបចំទីតាំងមួយដែលមានវិសាលវិហារមួយ ដែលមានកន្លែងដើម្បី ឲ្យបងប្អូនមកពីឆ្ងាយមកពីជិតមានកន្លែងស្នាក់នៅបាន ឲ្យអាចប្រជុំបាន ដើម្បីរិះគិតអំពីព្រះនាងម៉ារី ធ្វើសិក្ខាសាលា ធ្វើសំណាក់ធម៌ និងមានការអធិដ្ឋានច្បាស់លាស់ ។ ដូច្នេះជាឱកាសមួយ ដើម្បីជួយឲ្យព្រះសហគមន៍យើង រីកចម្រើនតាម



*លោកអភិបាលគោរពរូបសំណាកព្រះមាតានៃទន្លេមេគង្គនៅអរិយក្សត្រ*

ជំនឿដែរ។ ហើយខ្ញុំសង្ឃឹមនៅពេលព្រះជាម្ចាស់ ប្រទានលុយឲ្យយើងល្មម ហើយ យើងទៅមុខដោយសារយើងជឿលើឧបការគុណរបស់ព្រះជាម្ចាស់ "។

លោកអភិបាល មានប្រសាសន៍ទៀតថា ព្រះវិហារថ្មី នឹងមានក្នុងពេលឆាប់ៗនេះ ប្រសិនបើយើងមានប្រាក់គ្រប់គ្រាន់ តែបច្ចុប្បន្ន លោកអភិបាលកំពុងតែស្វែងរកថវិកា ពីសប្បុរសជនដើម្បីជួយគាំទ្រគម្រោងនេះ៕

*ដោយកល្យប្រឹក្ស*

# ការទទួលទានសត្វល្អិត មិនមែនជាការទទួល-ទានដែលគ្មានប្រយោជន៍



*សត្វល្អិតដាក់លក់នៅតំបន់ស្គន់តាមបណ្ដោយផ្លូវជាតិលេខ៦។*

រហូតមកដល់ពេលនេះ អ្នកទទួលទានសត្វល្អិតគឺមានច្រើន ហើយអ្នកដែលពេបជ្រាយ ឲ្យអ្នកដែលទទួលទានសត្វល្អិតក៏មានច្រើនដែរ ប៉ុន្តែតើមានប៉ុន្មាននាក់ដែលដឹង អំពីសក្តានុពល និង អត្ថប្រយោជន៍ នៃការទទួលទានសត្វល្អិតនេះដែរឬទេ?

ទាំងអ្នកដែលទទួលទាន និងអ្នកដែលពេបជ្រាយឲ្យអ្នកទទួលទាន សត្វល្អិតគួរយល់ថា សត្វល្អិត គឺជាប្រភេទអាហារ ដែលអាចផ្តល់នូវសារជាតុប្រូតេអ៊ីន មានប្រយោជន៍ជាច្រើន មិនខុសពីពពួកសត្វពាហនៈ ឬត្រីសាច់ផ្សេងៗ ដែលជាអាហារប្រចាំថ្ងៃរបស់មនុស្សទូទៅនោះទេ ។

មកដល់ពេលនេះ អាហារប្រភេទសត្វល្អិត គឺមានលក់គ្រប់ទិសទី ប៉ុន្តែកន្លែងដែលប្រមូលផ្តុំ ហើយអាចថាជាកន្លែងដែលលក់សត្វល្អិតនេះ ល្បីល្បាញជាងគេនោះ គឺនៅស្គន់ ដែលជាទីប្រជុំជនមួយតាមផ្លូវជាតិលេខ ៦ អាដែលមនុស្សម្នា ប្រជាពលរដ្ឋ និងភ្ញៀវបរទេស ធ្វើដំណើរពីភ្នំពេញទៅកាន់រមណីដ្ឋាននានា នៅក្នុងខេត្តសៀមរាប កំពង់ចាម កំពង់ធំជាដើម គឺត្រូវឆ្លងកាត់។

នៅទីនោះ អាហារដែលចម្អិនអំពីពពួកសត្វល្អិត គឺមានច្រើនថាស ច្រើនប្រភេទ ដែលកំពុងតែរង់ចាំផ្តល់ជូនបណ្តាអ្នកដំណើរ អ្នកទេសចរជាតិ និងអន្តរជាតិព្រមទាំងប្រជាពលរដ្ឋទូទៅ ។ ក្រៅពីអាហារ សត្វល្អិត ពពួកផលជាតិមានប្រយោជន៍ដល់រាងកាយ ជាច្រើនប្រភេទ ដែលផលិតនៅក្នុងស្រុក ដូចជា ចេកឆាប ផ្លែឈើ គឺនៅរង់ចាំទទួលលោកអ្នកផងដែរ ។

រហូតមកដល់ពេលនេះ សត្វល្អិតដែលគេអាចរកធ្វើជាអាហារ នៅទូទាំងពិភពលោក គឺមានសរុបប្រមាណជា ១.៩០០ ប្រភេទ ប៉ុន្តែនៅស្គន់ គឺមានប្រមាណជា បួន ប្រាំប្រភេទប៉ុណ្ណោះ ដែលជារួម គឺមានដូចជា សត្វកន្ទាទូក ដឹកដឿ (ដង្កូវនាង) អាពីង កូនកង្កែប-អាច់គោ កណ្តូប។ល។

លោកស្រី មី ផល្លា ជាអាជីវករលក់សត្វល្អិត នៅទីប្រជុំជនស្គន់មួយរូប បានឲ្យដឹងថា មកដល់ពេលនេះ អ្នកដែលនិយមទទួលទានសត្វល្អិត និងទទួលស្គាល់ថា វាគឺជាអាហារដែលមានរសជាតិមួយប្រភេទ គឺមានច្រើន ប៉ុន្តែអ្នកដែលបង្ហាញអារម្មណ៍រអើម ហើយស្ទាក់ស្ទើរមិនទទួលទាន ខ្លាចខ្ពើមគេក៏មានច្រើនដែរ ។

លោកស្រីបានបញ្ជាក់ថា "អ្នកខ្លះគេញុាំ អ្នកខ្លះគេមិនញុាំ ហើយក៏មានអ្នកខ្លះទិញ ដើម្បីសាកល្បងញុាំផងដែរ"។

លោកស្រីបានបន្តថា មកដល់ពេលនេះ ទីផ្សារអាហារសត្វល្អិតនៅស្គន់នេះ គឺប្រសើរ ហើយក៏កំពុងតែទាក់ទាញភ្ញៀវទេសចរមិនជាតិចប៉ុន្មានដែរ។

លោកស្រី បានបញ្ជាក់ថា "ភ្ញៀវទេសចរបរទេស ដូចតែខ្មែរយើងដែរ អ្នកខ្លះគេមិនញុាំទេ ប៉ុន្តែគេចុះថតរូបគេសប្បាយបានឃើញ យើងលក់សត្វទាំងនេះ"។

លោកស្រីបានបន្ថែមថា រហូតមកដល់ពេលនេះ បណ្តាភ្ញៀវទេសចរបរទេស ដែលចាប់អារម្មណ៍ទទួលទានទិញសត្វល្អិតនៅស្គន់ គឺមានដូចជា ចិនវៀតណាម កូរ៉េ ហើយពួកបារាំងខ្លះៗ (ភ្ញៀវទេសចរមកពីអឺរ៉ុប) ក៏បានញុាំផងដែរ ។

រហូតមកដល់ពេលនេះ ពពួកសត្វល្អិតទាំងនេះ ត្រូវបានលក់ជាកំប៉ុងតាមការរាប់។ល។ ដោយនៅក្នុងនោះដូចជា ចង្រិត ដឹកដឿ កណ្តូប គឺលក់មួយកំប៉ុង ១.៥០០ រៀល ហើយពពួកសត្វល្អិតមានទំហំធំបន្តិច ដូចជាអាពីង កន្ទាទូកអីនោះ គឺលក់មួយៗ ដោយខ្លះ ១០០០ខ្លះ ១.៥០០ រៀល ជាដើម ។

ទាក់ទងនឹងគុណតម្លៃនៃពពួកសត្វ-ល្អិតនេះ មានរបាយការណ៍មួយ ដែលសិក្សាស្រាវជ្រាវ ដោយអង្គការស្បៀងអាហារ និងកសិកម្មអង្គការសហប្រជា-ជាតិ ដែលគេហៅថា ហ្វាវ(FAO) បានឲ្យដឹងថា ពពួកអាហារដែលចម្អិនពីសត្វល្អិតនេះ គឺអាចជាប្រភពអាហារដែលចូលរួម ធានាសន្តិសុខស្បៀងអាហារពិភពលោក នៅពេលអនាគតបាន ។

អង្គការនេះ បានអះអាងថា តាំងពីឆ្នាំ២០០៣មក អង្គការ ហ្វាវ គឺបានកំពុងតែធ្វើការ ជាមួយនឹងប្រទេសជាច្រើនទាក់ទងនឹងសត្វល្អិតនេះ ។

អង្គការអន្តរជាតិ មួយនេះ បានអះអាងថា សត្វល្អិត គឺជាប្រភេទអាហារដែលអាចទទួលទានបាន ដោយសារតែវាមានប្រភពប្រូតេអ៊ីន វីតាមីន និងសារជាតុអាមីណូអាស៊ីត មានប្រយោជន៍សម្រាប់តម្រូវការ ទ្រទ្រង់រូបរាងកាយរបស់មនុស្ស ។

ប្រភពដដែលបានបន្តថា សត្វល្អិតគឺមាន សារជាតុមានប្រយោជន៍ច្រើន ហើយក៏អាចកាត់បន្ថយការពឹង ផ្អែកទាលើសត្វដែលជាអាហារទូទៅ។ ជាក់ស្តែងដូចជា ពពួកចង្រិត គឺងាយស្រួលចិញ្ចឹមជាងសត្វពាហនៈ រហូតដល់ទៅ ៦ដង ប៉ុន្តែវាមានអត្ថប្រ-យោជន៍ ជាងសាច់សត្វទាំងនោះផងដែរ។ ពពួកសត្វល្អិត គឺអាចនឹងងាយស្រួលចិញ្ចឹម ដោយសារពួកវា ត្រូវការតែពពួកកាកសំណល់សរីរាង្គ ដូច្នេះវាអាចកាត់បន្ថយកាកសំណល់ ហើយក៏អាចដោះស្រាយប្រភពអាហារ ដល់កំណើនប្រជាពលរដ្ឋបាន ។

តាមការព្យាករណ៍ នៅលើពិភពលោក នៅក្នុងឆ្នាំ២០៣០ នឹងមានប្រ-ជាពលរដ្ឋសរុបទាំងអស់ ប្រមាណជា ៩ ពាន់លាននាក់ ដូច្នេះគឺតម្រូវការការចិញ្ចឹមសត្វជាអាហារ រាប់ពាន់លានក្បាលដើម្បីផ្គត់ផ្គង់អាហារ ប៉ុន្តែបម្រែ-បម្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមមួយ ដូច្នេះសត្វល្អិតត្រូវបានគេអះអាងថា គឺជាប្រភពដ៏ចម្បង ៕

# ច្បាប់ចរាចរណ៍ ផ្លូវគោកថ្មី

**មាត្រាទី២៧៖**

ការប្រើប្រាស់ភ្លើងសញ្ញា ក្នុងករណីកំពុងបើកបរយាន ដែលមិនមែនជាយានយន្ត អ្នកបើកបរយានប្រភេទដូចខាងក្រោម ត្រូវអនុវត្តដូចតទៅ៖

- រទេះអូសទាញដោយមនុស្ស ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស ឬលឿងដាក់នៅខាងមុខ និងភ្លើង ឬ កញ្ចក់ចាំងពន្លឺពណ៌ក្រហមមួយដាក់នៅខាងក្រោយ ។ ភ្លើងទាំងពីរនេះ ដាក់នៅជ្រុងរទេះឈម នឹងទ្រូវផ្លូវ
- រទេះអូសទាញដោយសត្វ ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស ឬលឿងពីរដាក់នៅខាងមុខជ្រុងរទេះសងខាង និងត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមពីរដាក់នៅខាងក្រោយជ្រុងរទេះសងខាង
- ទោចក្រយាន និងត្រីចក្រយាន ត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ស យ៉ាងតិចមួយនៅខាងមុខ និងត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមយ៉ាងតិចមួយនៅខាងក្រោយ
- រ៉ឺម៉កសណ្តោង ដោយទោចក្រ-យានយន្ត នៅលើថ្នល់ផ្លូវ ដែលគ្មានភ្លើងអគ្គិសនីសាធារណៈបំភ្លឺ ត្រូវប្រើ៖
- ភ្លើងទីតាំង ៖ សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវ ដែលមក ពីខាង មុខឲ្យដឹងពីវត្តមានយាន និងទំហំទទឹងយាន
- ភ្លើងក្រហម ៖ សម្រាប់ប្រាប់ដំណឹង ដល់អ្នកប្រើប្រាស់ផ្លូវ ដែលមកពីខាងក្រោយ ឲ្យដឹងពីវត្តមានយាន និងទំហំទទឹងយាន
- ភ្លើងបំភ្លឺផ្លាកលេខ ៖ សម្រាប់ឲ្យគេ មើលលេខសម្គាល់យានជំនិះឃើញច្បាស់ពីខាងក្រោយ។

នៅទីប្រជុំជន ការប្រើប្រាស់ភ្លើងសញ្ញាដែលបានចែង ក្នុងចំណុច៣ នេះ មិនចាំបាច់ប្រើប្រាស់ទេ បើមានភ្លើងអគ្គិសនីបំភ្លឺ ហើយមានពន្លឺគ្រប់គ្រាន់ អាចឲ្យអ្នកប្រើប្រាស់ផ្លូវមើលយានបានច្បាស់ ពីចម្ងាយយ៉ាងតិច២០ (ម្ភៃ) ម៉ែត្រ៕

# កម្មករនិងកម្មការនីសន្យាបង្កើនផលិតភាពការងារតែសុំកុំឲ្យរដ្ឋជួយទប់ស្កាត់រឿងអតិផរណា



*កម្មករកម្មការិនីចេញពីរោងចក្រទិញអាហារថ្ងៃត្រង់។រូបថតៈ csc*

បណ្ដាកម្មករ និង កម្មការិនីតាមរោងចក្រកាត់ដេរ ដែលកំពុងតែធ្វើដំណើរវិលត្រឡប់ ពីការឈប់សម្រាកបុណ្យអុំទូក មកកាន់កន្លែងធ្វើការងារវិញ បានអះអាងថា នឹងខិតខំបង្កើនផលិតភាពការងាររបស់ខ្លួន ដោយសារតែឆ្នាំ ក្រោយ ពួកគេអាចទទួលបាននូវការតម្លើងប្រាក់ឈ្នួលមួយកម្រិតថែមទៀត ។

កញ្ញា លី ណៃសៀង ជាកម្មកររោងចក្រកាត់ដេរនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ បានអះអាងថា វាគឺជារឿងត្រេកអរ នៅមុនពេលសម្រាកភ្ជុំបិណ្ឌសម្រាប់កញ្ញា និង បណ្ដាកម្មករទាំងអស់ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សូមរដ្ឋជួយកុំឲ្យថ្លៃម្ហូបអាហារ ថ្លៃបន្ទប់ជួល ថ្លៃភ្លើង ថ្លៃទឹក ឡើងទៅបានហើយ។

កញ្ញា បានបញ្ជាក់ថា "បើសិនជារដ្ឋអាចជួយទប់ស្កាត់ ឲ្យតម្លៃចំណាយផ្សេងៗ របស់ពួកយើងនៅដដែល ដូចសព្វថ្ងៃនេះ ពួកយើងសប្បាយចិត្ត"។

កញ្ញា បានបន្តថា ការសម្រេចតម្លើងប្រាក់ខែ ១២ ដុល្លារ នៅក្នុងមួយខែនៅឆ្នាំក្រោយនេះ កញ្ញាសង្ឃឹមថានឹងអាចទទួលបាននូវប្រាក់ខែ សរុបប្រមាណជា ពី២០០ទៅ ២៥០ ដុល្លារដែរនៅក្នុងមួយខែ បើបូកទាំងថ្លៃថែមម៉ោង។

កញ្ញា បានបញ្ជាក់ថា "ប្រាក់ខែនេះគឺវាច្រើនជាងពេលដែលកញ្ញា ចាប់ផ្ដើមធ្វើការកាលពីប្រហែល ៥ ឆ្នាំមុន "។

លោកស្រី ចេង វិណៃ ជាកម្មការនីរោងចក្រកាត់ដេរ នៅម្ដុំចក្រអង្រែ បានអះអាងថា ពេលសហជីពប្រាប់ពួកយើង អំពីការសម្រេចតម្លើងប្រាក់ឈ្នួល ១២ដុល្លារនេះ កម្មករ និង កម្មការនីណាក៏មុខរីកដែរ។

ជុំវិញបញ្ហានេះ លោកស្រី វិណៃ បានឲ្យដឹងថា លុយ១២ ដុល្លារ នេះវាមិនច្រើនទេ សម្រាប់លោកស្រី ប៉ុន្តែយ៉ាងហោចណាស់ ក៏អាចដោះស្រាយរឿងថ្លៃបង់សាលាកូនរៀនអង់គ្លេសម្នាក់បានមួយខែនឹងគេផងដែរ ដូច្នេះលោកស្រី អាចកាត់បន្ថយបន្ទុកបានមួយចំណែកនៅក្នុងគ្រួសារ ថែមទៀតដែរ ប៉ុន្តែ បើនិយាយអំពីថ្លៃម្ហូបអាហារវិញ គឺអ្នកខ្លះអាច ដោះស្រាយបានមួយសប្ដាហ៍។

លោកស្រីបានបញ្ជាក់ថា"១២ដុល្លារនៅក្នុងមួយខែ មិនជាច្រើនទេ ប៉ុន្តែវាក៏មិនជាតិចដែរ។ លុយ ១២ ដុល្លារយ៉ាងហោចណាស់ ក៏អាចជួយដោះស្រាយថ្លៃអាហារពួកយើងម្នាក់ៗបាន ពី ៤ថ្ងៃ ទៅមួយអាទិត្យ ប្រសិនបើតម្លៃទំនិញមិនឡើង"។

លោកស្រីបានបន្តថា បើសិនជារដ្ឋមិនអាចទប់ស្កាត់ តម្លៃទំនិញបានទេ ពួកគេស្ថិតក្នុងស្ថានភាពដដែល ទោះបីជាប្រាក់ខែឡើងក៏ដោយ ។

ជាមួយនឹងការសន្យា តម្លើងប្រាក់ឈ្នួលប្រចាំខែ ១២ដុល្លារ បន្ថែមនៅដើមឆ្នាំក្រោយនេះ ទាំងលោកស្រី វិណៃ និង កញ្ញា ណៃសៀង គឺសុទ្ធតែអះអាងថា នឹងខិតខំធ្វើការថែមមួយកំរិតទៀត ដើម្បីឲ្យស័ក្តិសម និងការសម្រេចចិត្តនេះ។

កញ្ញា ណៃសៀង បានអះអាងថា ធម្មតាទេ មនុស្សយើងតែសប្បាយចិត្តធ្វើការងារក៏ល្អ ប្រិតប្រៀង ហើយបានទិន្នផលច្រើនថែមទៀត ដែលផ្ទុយពេលដែលពិបាកចិត្ត គឺច្រើនតែរវើរវាយគិតនេះគិតនោះ ដូច្នេះទិន្នផលការងារក៏ធ្លាក់ចុះទៅតាមនោះដែរ ។

កញ្ញា បានបញ្ជាក់ថា "មិនថាខ្ញុំមិនថាគេទេ ពេលសប្បាយចិត្ត គឺមានភាព ប្រាកដប្រជានៅក្នុងការបំពេញការងារ "។

លោកស្រីវិណៃ បានអះអាងថា ១២ ដុល្លារនេះ ថ្វីត្បិតតែវាមិនច្រើនសម្រាប់យើងម្នាក់ៗ ប៉ុន្តែបើសិនជាគិតម៉ារោងចក្រ គឺរាប់ពាន់ ដូច្នេះពួកយើងនឹងខិតខំធ្វើការបន្ថែមទៀត ដើម្បីទទួលផលទាំងអស់គ្នា។

ចាប់ពីខែ ១ ខែមករា ឆ្នាំ២០១៦ ខាងមុខនេះតទៅ កម្មករនិងកម្មការនីរោងចក្រកាត់ដេរនានា នៅទូទាំងប្រទេសកម្ពុជា នឹងទទួលបានប្រាក់ខែគោលយ៉ាងទាបបំផុត ១៤០ ដុល្លារ ខណៈដែល នៅពេលបច្ចុប្បន្ននេះ ពួកគេទទួលត្រឹមតែ ១២៨ ដុល្លារនោះ។

នៅទូទាំងប្រទេសកម្ពុជា គេបានដឹងថា មានរោងចក្រ ប្រមាណជា ១.០៨០ រោងចក្រ ដោយនៅក្នុងនោះ គឺមានកម្មករ និងកម្មការនីប្រមាណជា ៧០០.០០០នាក់។វិស័យឧស្សាហកម្មកាត់ដេរនេះ គឺអាចរកប្រាក់ចំណូលប្រមាណជា ៦,២ ពាន់លានដុល្លារ កាលពីឆ្នាំទៅ។

នៅក្នុង ឆ្នាំ២០១៥នេះ កំណើនសេដ្ឋកិច្ចកម្ពុជា គឺនៅតែមានស្ថានភាពរឹងមាំ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ កំណើននេះ នៅតែពឹងផ្អែកខ្លាំងទៅលើការនាំចេញផលិតផលនៃ ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង។

តាមការព្យាករណ៍ ទុករបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា កំណើនសេដ្ឋកិច្ចនៅក្នុងឆ្នាំ ២០១៥នេះ ត្រូវបានគេព្យាករណ៍ថា នឹងសម្រេចបាននៅក្នុងរង្វង់ ៧ភាគរយ អរគុណចំពោះកំណើន នៃការនាំចេញផលិតផល នៃឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ។

ជាមួយនឹងសញ្ញាវិជ្ជមាន នៃការរក្សាបាននូវកំណើនសេដ្ឋកិច្ច ឲ្យបន្តស្ថិតនៅថេរនៅក្នុងរង្វង់ ៧ភាគរយ នៅក្នុងមួយឆ្នាំនេះ នេះគេបានទស្សន៍ទាយថា កម្រិតអតិផរណាប្រចាំឆ្នាំ នឹងរក្សាបាននៅក្នុងកម្រិតមួយវិជ្ជមាន គឺត្រឹមតែ ១,៣ ភាគរយ ។

កាលពីក្នុងខែឧសភា ឆ្នាំ២០១៥ កំរិតអតិផរណានៅកម្ពុជា បានថយចុះ-ទាបពេលគឺត្រឹមតែ ១ ភាគរយប៉ុណ្ណោះ ដោយសារ តែការថយចុះ នូវការចំណាយលើការដឹកជញ្ជូន និងឥន្ទនៈក្រោយពេលមានការថយចុះយ៉ាងគំហុកនៃតម្លៃប្រេង ៕

## អាស៊ានកំណត់ផែនទីសម្រាប់សមាហរណកម្មប្រសើរជាងមុន

មេដឹកនាំ មកពីបណ្តាប្រទេសសមាជិកអាស៊ានទាំង ១០ បានជួបប្រជុំ នៅម៉ាឡេស៊ីជាថ្មីម្តងទៀត ក្នុងកិច្ចប្រជុំកំពូលទីពីរនាឆ្នាំនេះ បន្ទាប់ពីកិច្ចប្រជុំកំពូលដំបូង ដែលត្រូវបានធ្វើឡើងនៅក្នុង ខែមេសា បានបញ្ចប់រួចរាល់រួចមកនោះ ។

ប្រទេសម៉ាឡេស៊ី បានធ្វើជាម្ចាស់ផ្ទះ នៅក្នុងរយៈកាលសំខាន់មួយសម្រាប់អាស៊ាន ខណៈដែលឆ្នាំនេះត្រូវបានកំណត់កាលបរិច្ឆេទ នៃការបង្កើតសហគមន៍អាស៊ាន ដែលគេនឹងឃើញមាន ការរួមបញ្ចូលបានប្រសើរជាងមុន តាមរយៈសសរគ្រឹះចំនួនបីដែលមាន សន្តិសុខ នយោបាយ សេដ្ឋកិច្ច និងសង្គមវប្បធម៌។

លើសពីនេះទៀត បណ្តាមេដឹកនាំប្រទេសសមាជិកអាស៊ាន ក៏បានរៀបចំឡើងនូបរចនាសម្ព័ន្ធ សម្រាប់ " ទស្សនវិស័យសហគមន៍អាស៊ាន ២០២៥"ដែលក្រុមមេដឹកនាំទាំងនោះនឹងអនុម័តឡើង នៅក្នុងឯកសារដែលមានចំណងជើងថា "សេចក្តីប្រកាសកូឡាឡាំពួរទៅលើអាស៊ាន ២០២៥ ៖ ការជំរុញទៅមុខរួមគ្នា"។

នៅក្នុងសេចក្តីថ្លែងការណ៍ រួមក្រុមមេដឹកនាំអាស៊ាន ពួកគេបានទទួលស្គាល់ពីការផ្លាស់ប្តូរយុទ្ធសាស្ត្រផ្នែកភូមិសាស្ត្រយ៉ាងឆាប់រហ័សនៅក្នុងតំបន់៕

## ថ្ងៃទី២៦ ខែ តុលា ផ្ទុះអំពើហិង្សាវាយប្រហារតំណាងរាស្ត្រពីររូប

ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០១៥ តំណាងរាស្ត្រគណបក្សប្រឆាំង គឺ គណបក្សសង្គ្រោះជាតិ ចំនួនពីររូប បានត្រូវជនដៃដល់មួយក្រុម សម្រុកវាយប្រហារ បណ្តាលឲ្យរងរបួស និង ខូចខាតយានយន្ត ។

ការវាយប្រហារនេះ បានកើតមានឡើង នៅក្នុងថ្ងៃដែលមានបាតុកម្មពីសំណាក់ប្រជាពលរដ្ឋដែលមក ពី១២ ខណ្ឌនៅក្នុងរាជធានីភ្នំពេញ ទាមទារឲ្យលោកកឹមសុខាជាអនុប្រធានគណបក្សសង្គ្រោះជាតិ ចុះចេញពីតំណែងអនុប្រធានរដ្ឋសភាទីមួយ ដោយលើកឡើងថា រយៈពេលកន្លងមកនេះ គឺលោកបានធ្វើសកម្មភាពឃោសនា បោកប្រាស់ ញុះញង់ បំបែកបំបាក់ បង្កអស្ថិរភាព ព្រមទាំងធ្វើការអុកឡុក បង្កឲ្យមានកំហឹងពូជសាសន៍ និងអាចឈានបង្កឲ្យមានសង្គ្រាម កើតមានក្នុងផ្ទៃប្រទេស ដែលសកម្មភាពទាំងនេះ គឺពិតជាមិនស័ក្តិសមជាថ្នាក់ដឹកនាំ នៃស្ថាប័នកំពូលរបស់ជាតិទេ។

តំណាងរាស្ត្រ ដែលរងរបួសទាំងពីរនាក់ គឺរួមមាន លោក ញ៉យ ចំរើន តំណាងរាស្ត្រមណ្ឌលកំពង់ចាម និង លោក គង់ សុភា តំណាងរាស្ត្រមណ្ឌលស្វាយរៀង ។

បន្ទាប់ពីហេតុការណ៍នេះ កើតមានឡើង គណបក្សសង្គ្រោះជាតិ និង មន្ត្រីរដ្ឋាភិបាល បានចេញសេចក្តីថ្លែងការថ្កោលទោស និង អំពាវនាវឲ្យចាប់ជនដៃដល់ ដែលបានវាយអ្នកតំណាងរាស្ត្រទាំងពីរនាក់នោះឲ្យរបួស យកទៅផ្តន្ទាទោស ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានសរសេរក្នុងហ្វេសប៊ុកថា អំពើហិង្សាមិនមែនជាសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិទេ ហើយការប៉ះពាល់ដល់រូបរាងកាយ ត្រូវបានគាំពារដោយច្បាប់៕

## ចិនប្រកាសបោះទុន ៣១,៤ ពាន់លានដុល្លារនៅតំបន់សេដ្ឋកិច្ចជាប់នឹងប្រទេសឡាវ

ចិនបានប្រកាសថា ខ្លួននឹងធ្វើការវិនិយោគ ៣១,៤ ពាន់លានដុល្លារនៅក្នុងតំបន់សេដ្ឋកិច្ច ម៉េនក្លា ក្នុងខេត្តយូណាន ដែលមានព្រំដែនជាប់ជាមួយនឹងខេត្ត លូណាក ណាមថា និង ផុងសាលី នៅភាគខាងជើងឡាវ។

ការវិនិយោគនោះ នឹងមានទៅលើគម្រោងជាង ២៤០ នៅក្នុងវិស័យផ្សេងៗ ដូចជា វិស័យដឹកជញ្ជូន អប់រំ និងថាមពលសម្រាប់តំបន់ម៉េនក្លា នៅតំបន់ស្វយ័តស៊ីសងបាណា ដៃ (Xishuangbanna Dai) ក្នុងខេត្ត ដែលមានផ្ទៃក្រឡាសរុប ប្រមាណជា ៤.៥០០ គីឡូម៉ែត្រការ៉េ ដោយផែនការនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិ ចិន កាលពីពេលថ្មីៗនេះ។

កាលពីខែមុន រដ្ឋាភិបាលឡាវ និង ចិន បានចុះហត្ថលេខាលើកិច្ចសហប្រតិបត្តិការ នៅក្នុងការបង្កើតតំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៅតំបន់ព្រំដែនប៉ូតេនម៉ូហាន នៅក្នុងគោលដៅជំរុញពាណិជ្ជកម្មវិនិយោគ និងទេសចរណ៍នៅក្នុងតំបន់។

កិច្ចព្រមព្រៀងនោះ ត្រូវបានចុះហត្ថលេខា នៅប្រទេសចិន រវាងឧបនាយករដ្ឋមន្ត្រីឡាវ ទទួលបន្ទុកផ្នែកកិច្ចការសេដ្ឋកិច្ច លោក សមសាវ៉ាត ឡេងសាវ៉ាត និងរដ្ឋមន្ត្រីពាណិជ្ជកម្មចិន លោក ការ ហ៊ូចេង។

នេះជាកិច្ចសហប្រតិបត្តិការ លើតំបន់សេដ្ឋកិច្ចឆ្លងព្រំដែនទីពីរ ដែលចិនបានបង្កើតឡើងជាមួយ នឹងប្រទេសជិតខាងខ្លួន ដែលនឹងជាកត្តាជំរុញកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចយ៉ាង ខ្លាំងនៅក្នុងតំបន់៕

## ជនពិការប្រមាណជាជិត ២០០០ នាក់ត្រូវបានជ្រើសរើសចូលបម្រើការងារ

លោក ឯម ច័ន្ទមករា អគ្គលេខាធិការនៃក្រុមប្រឹក្សា សកម្មភាពជនពិការ បានឱ្យដឹងថា មកដល់ពេលនេះ ជនពិការប្រមាណជា ២.០០០នាក់ ត្រូវបានជ្រើសរើសឲ្យចូលបម្រើការងារ នៅតាមក្រសួង មន្ទីរ និងស្ថាបនរដ្ឋនានា ស្របតាមគោលការណ៍ របស់រាជរដ្ឋាភិបាល ដែលកំណត់ផ្តល់សិទ្ធិ ដល់បងប្អូនប្រមាណជា២ភាគរយ ។

ថ្លែងនៅក្នុងពិធី សម្ពោធប្រើជាផ្លូវការ នូវគោលការណ៍ណែនាំស្តីពីអង្គការជនពិការ និងកិច្ចប្រជុំបណ្តាញប្រចាំឆ្នាំរបស់អង្គការពិការកម្ពុជា លោកបានមានប្រសាសន៍ថា សព្វថ្ងៃមានជនពិការ ចូលបម្រើការងារសរុបចំនួន ១,៩៩៩នាក់ ស្មើនឹង១.២៦ភាគរយ ។

លោកបន្តថា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចនូវសមិទ្ធផលជាច្រើន ក្នុងវិស័យពិការភាព សំដៅឲ្យជនពិការ និងក្រុមគ្រួសារ មានគុណភាពជីវិតល្អប្រសើរ និងចូលរួមយ៉ាងសកម្ម ពេញលេញស្មើភាពគ្នាក្នុងសង្គម ដែលមានការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរ ព្រមទាំងបញ្ចូលបញ្ហាពិការភាពទៅក្នុងគ្រប់វិស័យ តាមរយៈការជំរុញឲ្យចូលរួមពីស្ថាប័នរដ្ឋ ឯកជនសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍ ប្រកបដោយ ចីរភាពសម្រាប់ជនពិការកម្ពុជាគ្រប់រូប។

លោក ងិន សៅរ័ត្ន នាយកប្រតិបត្តិនៃអង្គការជនពិការកម្ពុជា បានមានប្រសាសន៍ថា តាមរយៈការទទួលយកពួកគាត់ ឱ្យចូលបំរើការងារ វាជាការជួយសម្រួល ដល់ជីវភាពរស់នៅរបស់ពួកគាត់ និងក្រុមគ្រួសារបានសមរម្យដូចគេឯង។

នៅថ្ងៃដដែលនេះ អង្គការយូនីសេហ្វ បានប្រកាសផ្តល់ថវិកា ចំនួន៤០ម៉ឺនដុល្លារ ដល់អង្គការដៃគូចំនួន៦ សម្រាប់ពួកគេផ្តល់សេវាកម្មសហគមន៍ ប្រកបដោយគុណភាពដល់ជនពិការ ជាពិសេស ដល់ស្ត្រី និងកុមារនៅក្នុងខេត្តចំនួន១២ និងរាជធានីភ្នំពេញពីឆ្នាំ ២០១៥-២០២០។

អង្គការទទួលថវិកាទាំងនេះរួមមាន អង្គការការីតាសកម្ពុជា អង្គការជនពិការអន្តរជាតិ អង្គការមូលនិធិកុមារពិការ អង្គការគ្រួសារថ្មី អង្គការអភិវឌ្ឍន៍សមត្ថភាព ជនពិការតាមសហគមន៍ និង មជ្ឈមណ្ឌលជីវិតរស់នៅឯករាជ្យនៃជនពិការភ្នំពេញ៕

# ថ្ងៃបង្កើតសហគមអាស៊ានកាន់តែកៀក តែពលរដ្ឋបាន

ពលរដ្ឋកម្ពុជា ដឹងអំពីកាលបរិច្ឆេទនៃការប្រកាសសហគមន៍អាស៊ាន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើនគឺបានត្រឹមតែដឹង រីឯការស្វែងយល់ស៊ីជម្រៅគឺមានតិចតួច ហើយមានតែនៅក្នុងចំណោមនិស្សិត មន្ត្រីរាជការ និង សង្គមស៊ីវិល ព្រមទាំងក្រុមហ៊ុនដែលពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ ដែលជ្រួតជ្រាបបានច្បាស់។

ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥ ត្រូវនឹងថ្ងៃព្រហស្បតិ៍ គឺជាថ្ងៃដែលអាស៊ានបានកំណត់ គឺជាថ្ងៃប្រកាស ប្រែក្លាយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា អាស៊ាននេះ ឲ្យទៅជាសហគមន៍អាស៊ាន ពោលគឺ បណ្ដាមេដឹកនាំអាស៊ានទាំង ១០ ប្រទេស រួមទាំងកម្ពុជា គ្រោងនឹងប្រកាប់ប្រជាជនប្រមាណជា ៦០០ លាននាក់ ដែលមានវប្បធម៌ភាសា កំរិតនៃការអភិវឌ្ឍន៍ផ្សេងៗគ្នា ឲ្យរួមគ្នាជាវាសនាតែមួយ ។

លោក ស្វាយ ចេតនា ជាប្រជាពលរដ្ឋរស់នៅម្ដុំអូឫស្សីបានអះអាងថា តាមការយល់ដឹងរបស់លោក នរណាៗឲ្យតែជាអ្នកធ្វើការ មានចំណេះដឹង ចេះតាមដានព័ត៌មាន គឺសុទ្ធតែបានដឹងអំពីការបង្កើតសហគមន៍អាស៊ាននេះ គ្រាន់តែរឿងស៊ីជម្រៅទៅទៀត វាមិនដឹងដូចគេអ្នកធ្វើការ។

លោកបានបញ្ជាក់ថា "បើត្រឹមតែព័ត៌មាន អំពីការបង្កើតសហគមន៍អាស៊ាននេះ មេដឹកនាំកម្ពុជា និងអ្នកនយោបាយ បញ្ញវ័ន្ត និយាយសឹងតែរាល់ថ្ងៃគ្រាន់តែយើងមិនសូវតាមដាន"។

លោកបានបន្តទៀតថា សម្រាប់ប្រជាពលរដ្ឋនៅតាមខេត្ត តាមជនបទអីនោះ បើសិនជាតាមដានព័ត៌មាន គឺសុទ្ធតែបានដឹងអំពីគម្រោងការបង្កើតសហគមន៍អាស៊ាននេះដែរហើយ ប៉ុន្តែគ្រាន់តែថាស៊ីជម្រៅវាលំបាក។

លោក ជ័យ យុទ្ធាបុទ្ធ ដែលបានអះអាងថា គឺជាមន្ត្រីរាជការ នៅខេត្តបាត់ដំបងមួយរូប បានអះអាងថា នៅលើរថយន្តក្រុង ដែលកំពុងតែធ្វើដំណើរពីភ្នំពេញទៅបាត់ដំបងថា រឿងអាស៊ាននេះលោកដឹង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយគឺបានត្រឹមតែដឹងប៉ុណ្ណោះ ។

លោកបានបញ្ជាក់ថា "រឿងអាស៊ានរឿង បង្កើតសហគមន៍អាស៊ានអីនោះ គឺទាំងខ្ញុំទាំងគេចេះតែដឹង ចេះតែឮនឹងគេហើយ គ្រាន់តែមិនស៊ីជម្រៅដូចគេជាមន្ត្រីធំៗ សិស្សនិស្សិត ដែលគេរៀនសូត្រជ្រៅជ្រះ"។

លោកបានបន្តថា នេះវាមិនមែនជាការងារយើង ដូច្នេះហើយបានជាមិនសូវតាមដាន ទើបបានជាមិនដឹងអ្វីជ្រៅជ្រះដូចគេ ប៉ុន្តែគ្រាន់តែមកដល់ពេលនេះ មានគេនិយាយថា ការបង្កើតសហគមន៍អាស៊ាននេះ គឺមានទាំងឱកាស និងការប្រឈម ។

លោកបានបន្តថាបើជា ឱកាសនោះវាមិនមែនជាបញ្ហាទេ យើងចូលនឹងគេគឺជារឿងដែលល្អ ប៉ុន្តែចំណុចប្រឈមនេះជាបញ្ហា ដែលគួរយកចិត្តទុកដាក់ដូច្នេះហើយ បានជាចេះតែប្រាប់កូនដែលមកសិក្សានៅភ្នំពេញ ឲ្យចេះស្វែងយល់ពីបញ្ហាទាំងអស់នោះ ។

លោកបានបញ្ជាក់ទៀតថា "ដូចខ្ញុំនេះ ចំណាស់ដល់ទៅ៥៥ ហើយទៅខ្វល់ខ្វាយអ្វីច្រើនរឿងអាស៊ាន រឿងសហគមន៍ស្អីនោះ យ៉ាងច្រើនរស់បាន ១០ ទៅ២០ ឆ្នាំទៀត ប៉ុន្តែកូនខ្ញុំកូនគេគឺត្រូវ តែយកចិត្តទុកដាក់"។

លោកបានបន្តថា តាមព័ត៌មានសម្ដេចហ៊ុន សែន និយាយតាមវិទ្យុប៉ុន្មានថ្ងៃមុននេះឮថា ជិតដល់ថ្ងៃបង្កើតសហគមន៍អាស៊ាននេះហើយ ដូច្នេះហើយបានជាលោក តែងតែផ្ដាំផ្ញើកូនឲ្យស្វះស្វែងរៀនសូត្រ ក្រែងលោអាចមានឱកាស ចេញទៅធ្វើការនៅក្រៅប្រទេសអី ដូចជាគេបានផ្សាយក្រោយពេលសមាហរណកម្មនេះ។

រហូតមកដល់ពេលនេះ នៅក្នុងចំណោមនិស្សិតនៅកម្ពុជាវិញ ជាទូទៅមិនបានគិតគូរ ទៅដល់ឱកាសដែលពួកគេអាចមានសមត្ថភាពចេញ ទៅប្រកួតប្រជែងការងារ នៅក្រៅប្រទេសនោះទេ ផ្ទុយទៅវិញ អ្វីដែលពួកគេបារម្ភនោះ គឺការដែលបរទេស ត្រូវចូលមកដណ្ដើមចំណែកទីផ្សារការងារ ដែលមានបន្តិចបន្តួចនៅក្នុងប្រទេស ទៅវិញទេ ។

កញ្ញា សួន ឡាវ ជានិស្សិត ឆ្នាំទីបីនៅ សាកលវិទ្យាល័យភូមិន្ទភ្នំពេញមួយរូប ដែលទំនងជាបានតាមដាន និងសិក្សាស្វែងយល់អំពីសហគមន៍អាស៊ានជាពិសេសគឺ សរសេរស្គម្ភមួយ នៃការបង្កើតសហគមន៍នោះ គឺសហគមន៍សេដ្ឋកិច្ចអាស៊ាន បានអះអាងថា មជ្ឈដ្ឋាននិស្សិត គឺកំពុងតែមានការបារម្ភមែនទែន អំពីការប្រកួតប្រជែង




*ជំនួបលើកទី៤០ រវាងថ្នាក់ដឹកនាំអាស៊ានកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥។*

ដណ្ដើមទីផ្សារការងារ ជាមួយនឹងប្រទេសដទៃ ។

កញ្ញាបានបញ្ជាក់ថា "យើងពិតជាព្រួយបារម្ភមែនទែន អំពីការប្រកួតប្រជែងទីផ្សារការងារនៅ ពេលសហគមន៍សេដ្ឋកិច្ចអាស៊ានមកដល់"។

កញ្ញាបានអះអាងថា សម្រាប់កញ្ញានិងមិត្តភក្ត្រផ្ទាល់យល់ថា ការមកដល់នៃសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាពេលវេលាមួយដ៏ឆាប់មែនទែន ដោយសារតែសមត្ថភាពទាំងខ្ញុំនិង យុវនិស្សិត និង យុវជនខ្មែរនៅពេលនេះ ភាគច្រើនមិនអាចមានសមត្ថភាព នៅក្នុងការប្រកួតប្រជែងជាមួយនឹង យុវជន និងនិស្សិតមកពីសិង្ហបុរី ពីម៉ាឡេស៊ី ពីហ្វីលីពិនអ្វីបានទេ ។

លោក ចាន់ សេងលៀប ជានិស្សិតវិស្វកម្មឆ្នាំទីពីរ មកពីខេត្តកំពង់ចាមមួយរូបបានចែករំលែក នៅការព្រួយបារម្ភ នៅពេលដែលសហគមន៍អាស៊ាន ពោលគឺ សហគមន៍សេដ្ឋកិច្ចអាស៊ាន នឹងមកដល់នូវចុងខែក្រោយនេះ។

លោកបានបញ្ជាក់ថា "យុវជនកម្ពុជាប្រហែលជា នឹងបាត់បង់ផលប្រយោជន៍ពេលដែល សហគមន៍សេដ្ឋកិច្ចអាស៊ានមកដល់"។

" ធៀបជាមួយនឹងសិ
គិតថា យើងប្រហែ
សហគមន៍នេ

យុវជន ជុំ គីមសាន ជាសិស្សវិទ្យាល័យ ដែលទើបប្រឡងជាប់សញ្ញាប័ត្រទុតិយភូមិមួយរូប អះអាងថា ប្អូនក៏មានការព្រួយបារម្ភផងដែរ អំពីទីផ្សារការងារទៅអនាគត ដោយសារតែកាលវិភាគ និងការសិក្សាអំពីសហគមន៍អាស៊ាន ដែលមានសហគមន៍សេដ្ឋកិច្ចជាដើមនោះ គឺតិចមែនទែន។

គីមសាន បានអះអាងថា "ធៀបជាមួយនឹងសិស្សនៅប្រទេសដទៃ ខ្ញុំគិតថា យើងប្រហែលជា យល់ដឹងអំពីសហគមន៍នេះតិចជាងគេ" ។

ប្អូនបានបន្តទៀតថា "ខ្ញុំទើបតែចាប់ផ្ដើមរៀន យើងនឹងប្រកាសចូលសហគមន៍អាស៊ានដែរ ដូច្នេះទម្រាំខ្ញុំរៀនមហាវិទ្យាល័យចប់ ៤ ឆ្នាំ ទីផ្សារការងារស្រុកយើងតិចផង ខ្ញុំខ្លាចគេមកដណ្ដើមការងារយើងអស់"។

កញ្ញា ហេង មុនីនិច ជានិស្សិតភាសា

# ត្រឹមតែដឹងអំពីកាលបរិច្ឆេទ




។រូបថត: AKP

*ស្សនៅប្រទេសដទៃ ខ្ញុំ លជាយល់ដឹងអំពី ះតិចជាងគេ ។ "*

អង់គ្លេសឆ្នាំទីបី ក៏បានសំដែងនូវការព្រួយបារម្ភអំពីថ្ងៃមកដល់ នៃការប្រកាសសហគមន៍អាស៊ាននេះផងដែរ ។

កញ្ញាបានអះអាងថា "នៅពេលនោះ អ្វីដែលខ្ញុំព្រួយ គឺថាយើងមិនអាចទៅប្រទេសគេបាន ប៉ុន្តែគេវិញបែរជាមកធ្វើការពេញនៅក្នុងស្រុក ដោយសារតែពេលនោះ ឱកាសគឺស្មើគ្នាសម្រាប់មនុស្សនៅក្នុងតំបន់ ប៉ុន្តែយើងបារម្ភរឿងសមត្ថភាព" ។

លោក ឈាង វណ្ណរិទ្ធ អ្នកស្រាវជ្រាវ និងជាសាស្ត្រាចារ្យខ្មែរ នៅសាកលវិទ្យាល័យ លីត នៅប្រទេសអង់គ្លេសមួយរូប បានមានប្រសាសន៍ថា លំហូរនៃពលកម្ម គឺជាភាពឈ្នះឈ្នះមួយសម្រាប់បណ្តារដ្ឋជាសមាជិក អាស៊ានទាំងអស់។

លោកបានបញ្ជាក់ថា "កត្តានេះ វាបង្កើតជាការប្រកួតប្រជែង ដែលនាំឲ្យមានទិន្នផលដោយសារតែលំហូរ នៃជំនាញពលកម្ម នាំឲ្យមានការចល័តនៃជំនាញនៅក្នុងតំបន់ ហើយក៏ឈានដល់ការផ្លាស់ប្តូរនិងកែលំអរជំនាញ" ។

រហូតមកដល់ពេលបច្ចុប្បន្ននេះមានជំនាញចំនួន ៧ ដែលត្រូវបានបណ្តាមេដឹកនាំអាស៊ានទាំង ១០ ដែលមានប្រទេសកម្ពុជា វៀតណាម ឡាវ ភូមា ប្រុយណេ ហ្វីលីពិន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី និង ប្រទេសថៃ បានយល់ព្រម និងទទួលស្គាល់ជំនាញទាំង ៧ នេះ ទៅវិញទៅមក ដែលមានដូចជា វិស្វកម្ម គិលានុបដ្ឋាកយិការ ស្ថាបត្យកម្ម ការអង្កេតដី វេជ្ជសាស្ត្រ ទន្តសាស្ត្រ និងគណនេយ្យ ។

លោក សាស្ត្រាចារ្យ បានបន្តថា នៅពេលអនាគតនេះ បណ្តាប្រទេសអាស៊ាននឹងបន្តទទួលស្គាល់ទៅវិញទៅមក នៅមុខជំនាញផ្សេងៗទៀត។

លោក សាស្ត្រាចារ្យ ក៏បានជំរុញឲ្យយុវនិស្សិតកម្ពុជា ត្រូវតែត្រៀមខ្លួន ដើម្បីជំរុញការប្រកួតប្រជែង ជាមួយនឹងបណ្តាប្រទេសនានា ដោយស្មើភាព៕

*ដោយអរិយបុត្រ*

## កម្ពុជាជាប្រទេសក្មេងខ្ចី ប៉ុន្តែសក្តានុពល គឺមាន

មកដល់ពេលនេះកម្ពុជា គឺជាកូនពៅនៅក្នុងអាស៊ាន ប៉ុន្តែមានកិច្ចការជាច្រើនដែលកម្ពុជា បានសម្រេចជោគជ័យ ទោះបីជាកម្ពុជាក្មេងខ្ចីជាងគេក៏ដោយ។

លោកស្រី រតនៈភូរិ កាឡេបូត នាយកប្រតិបត្តិនៃសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជា បានអះអាងថា នៅក្រោមទិដ្ឋភាពមួយចំនួន គឺថាកម្ពុជានៅតែជាប្រទេសមួយដែលក្មេងខ្ចីនៅក្នុងតំបន់ ប៉ុន្តែកត្តាធនធានមនុស្ស គឺជាអ្វីដែលមានការប្រែប្រួលខ្លាំងធៀបនឹង ២០ ឆ្នាំមុន ហើយជាមួយនឹងការវិវត្តន៍នេះ កម្ពុជានឹងទទួលបានផល ពីបណ្តាក្រុមហ៊ុនបរទេស ដែលមកបណ្តាក់ទុន និងបើកអាជីវកម្មនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីសហគមន៍សេដ្ឋកិច្ចអាស៊ាន បានមកដល់។

លោកស្រីបានបញ្ជាក់ថា "សម្រាប់កម្ពុជា ខ្ញុំមើលមិនឃើញពីហានិភ័យដែលកម្ពុជាអាចនឹងប្រឈមទាល់តែសោះ ប៉ុន្តែកម្ពុជាត្រូវការឲ្យមានការលើកទឹកចិត្តច្រើន"។

លោកស្រីបានអះអាងថា កម្ពុជាត្រូវការឲ្យមានការលើកទឹកចិត្តប្រជាពលរដ្ឋបន្តិច ដើម្បីប្រកួតប្រជែងជាមួយនឹង ប្រជាពលរដ្ឋមកពីប្រទេសផ្សេងៗនៅក្នុងតំបន់។

លោកស្រីបានបន្តថា លោកស្រីមិនទាន់មើលឃើញនូវលំហូរពលរដ្ឋពីខាងក្រៅច្រើនមកស្វែងរកការងារ និងដណ្តើមការងារពីប្រជាពលរដ្ឋខ្មែរនៅឡើយទេ ។

កម្ពុជាបានក្លាយជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអគ្នេយ៍ ហៅកាត់ថាអាស៊ាននេះនៅក្នុង ខែ មេសា ឆ្នាំ១៩៩៩ ប៉ុន្តែនៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥ នេះកម្ពុជានឹងរួមជាមួយនឹងអាស៊ានទាំង ១០ រួមគ្នា ប្រែក្លាយទៅជាសហគមន៍តែមួយថែមទៀត ។

## តើកម្ពុជាគួរធ្វើអ្វី ដើម្បីឲ្យសមាហរណកម្មនេះដំណើរការដោយរលូន

លោក ឈាង វណ្ណរិទ្ធ អ្នកស្រាវជ្រាវ និងជា សាស្ត្រាចារ្យខ្មែរនៅសាកលវិទ្យាល័យ លីត នៅប្រទេសអង់គ្លេសមួយរូប បានមានប្រសាសន៍ថា កម្ពុជាត្រូវការនូវបដិវត្តនូវការបណ្តុះបណ្តាលជំនាញមួយ។

លោកបានមានប្រសាសន៍ថា ការធ្វើបដិវត្តជំនាញនេះ គឺត្រូវការចូលរួមទាំងអស់គ្នាទាំងសារធាណ និងឯកជនដើម្បីពង្រឹងសមត្ថភាពយុវជន នៅក្នុងការប្រកួតប្រជែង ហើយមិនតែប៉ុណ្ណោះ យុវជនខ្លួនឯងក៏ត្រូវតែរៀបចំខ្លួនឯងដើម្បីប្រកួតប្រជែង ។

លោកបានបញ្ជាក់ថា គ្មានកិច្ចប្រឹងប្រែងណាមួយដែលអាចសម្រេចបានដោយសារតែមិនមានធនធានហិរញ្ញវត្ថុ និងធនធានមនុស្សនោះទេ ។

ជុំវិញបញ្ហាសមាហរណកម្មអាស៊ាននេះ លោក ហង្ស ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡាបានមានប្រសាសន៍ថា ក្រសួងគឺមានកម្មវិធីដែលជួយផ្តល់ការយល់ដឹងអំពីសហគមន៍អាស៊ាន ជាពិសេសគឺសហគមន៍សេដ្ឋកិច្ចអាស៊ាន ផ្តល់ជូនយុវជន ដើម្បីសិក្សានិងស្វែងយល់អំពីអាស៊ានផ្សេងៗទៀត។

លោកបានបន្តទៀតថា ការពង្រឹងគុណភាពនៃវិស័យអប់រំ ចំណេះទូទៅ ជាពិសេសគឺការប្រឡង សញ្ញាប័ត្រទុតិយភូមិ ក៏ជាផ្នែកមួយនៃការចូលរួមរបស់ក្រសួង ដើម្បីរៀបចំសម្រាប់ការធ្វើសមាហរណកម្មអាស៊ាននេះផងដែរ ។

# មរណសាក្សីនៅប្រទេសកម្ពុជា

នៅអំឡុងឆ្នាំ ១៩៧០ ដល់ ឆ្នាំ ១៩៧៨ ប្រទេសកម្ពុជា ចូលក្នុងសង្គ្រាមស៊ីវិល រវាងគោលនយោបាយខាងសេរី និងខាងកុម្មុយនិស្ត។ ទ្រឹស្តីដូមីណូ ដែលជាការដួលរលំ របស់ប្រទេសកាន់លទ្ធិ ប្រជាធិបតេយ្យ នៅតំបន់ជ្រោយឥណ្ឌូចិន ក្លាយទៅជាប្រទេសកុម្មុយនិស្ត។

នៅប្រទេសកម្ពុជា សង្គ្រាមចាប់ផ្តើមនៅឆ្នាំ ១៩៧០ ក្រោយដួររបបស្តេច ក្លាយទៅជារបបសាធារណរដ្ឋ ដោយការវាយលុករបស់កងទ័ពវៀតកុង ដែលចាប់ផ្តើមមានសកម្មភាព តាមជនបទ និងតាមខេត្តនានា។ រដ្ឋាភិបាល របស់ លន់ នល់ ប្រឆាំងពួកវៀតកុងជាផ្លូវការ ដោយបណ្តេញជនជាតិវៀតណាមទាំងអស់ទៅស្រុកវិញ ហើយមានការសម្លាប់ពួកគេយ៉ាងច្រើន។ នោះបណ្តាលឲ្យប៉ះពាល់ ដល់ព្រះសហគមន៍យ៉ាងខ្លាំង ដោយសារគ្រីស្តបរិស័ទ ដែលភាគច្រើន ជាជនជាតិវៀតណាម ត្រូវយល់ច្រឡំថា វៀតណាមទាំងអស់នៅកម្ពុជា ជាពួកវៀតកុង។

ព្រះវិហារទាំងអស់ ដែលមានជនជាតិវៀតណាម ត្រូវបិទចោល ដោយចោទថា ជាកន្លែងទុកគ្រាប់រំសេវឬជាទីជំរកពួកវៀតកុង។

សាសនាគ្រីស្តត្រូវបានគេស្អប់ដោយសារគេចាត់ទុកថា ជាសាសនាជនបរទេស។

នៅភូមិភាគកំពង់ចាម លោកអភិបាល ឡឺស៊ូអែហ្វ (Mgr.Leosouef) បានធ្វើអន្តរាគមន៍ សុំទុកជីវិតជនជាតិវៀតណាម ហើយលោក ប៉ុងសូដ៍ បានជួលនាវា ដឹកពួកគេទៅស្រុកវៀតណាមវិញ។

ហើយព្រះវិហារ និងសាលារៀនកាតូលិកជាច្រើន ក្លាយទៅជាជំរកសម្រាប់ជនភៀសខ្លួន ជាពិសេសនៅទីក្រុងភ្នំពេញ។

លោកវ៉ាំងសង់ រ៉ូឡាំង (Vincent Rollin) និង លោក ហ្វ្រង់ស័រក្លូ (Francois Claudel) ដែលជាក្រុមមរណសាក្សីដំបូង ដោយបូជាជីវិត ដើម្បីជួយជនភៀសខ្លួន។ លោកធ្វើដំណើរទៅអ្នកលឿង ហើយត្រូវវៀតកុងចាប់នៅតាមផ្លូវ។ ក្រោយមក មានលោកក្រាណិច (Noel Grannec) ដែលត្រូវវៀតកុង ចាប់យកទៅសម្លាប់នៅដីក្រហម និងលោកយ៉ូហានកាដួរ (P. Jean Cadour) ដែលត្រូវសម្លាប់នៅខេត្តក្រចេះ បន្ទាប់ពីវៀតកុងយកក្រុងនេះបាន។ លោកទាំងអស់ គឺជាសមាជិកក្រុមសាសនទូតក្រៅប្រទេស ក្រុងប៉ារីស(MEP)។ លោកថ្វាយជីវិតទៅកាន់ព្រះជាម្ចាស់ ដើម្បីបង្ហាញធម៌មេត្តារបស់ព្រះអង្គដល់ជនរងទុក្ខវេទនា ដោយសុខចិត្ត រួមរស់ជាមួយប្រជាជនមិន ត្រឡប់ទៅស្រុកវិញ។

នៅឆ្នាំ ១៩៧២ លោកសិលា ៉រ៉ាបុំាង (Pierre Rapin) ទទួលខុសត្រូវភូមិក្តុលលើ រួមជាមួយ ជាមួយលោកសិលា ឡេធឿងឌុង (Pierre LeThuongDung) និង លោកមីសែល តាន់ (Michel TAN)ដែលជាលោកបូជាចារ្យវៀតណាម ទទួលខុសត្រូវព្រះសហគមន៍នៅបឹងកាដោត។

ពេលនោះកម្មាភិបាលហាមបង្រៀនសាសនាទៀត។ លោកតាន់ឈឺស្លាប់ តែលោក៉រ៉ាបុំាង ត្រូវគ្រាប់បែកស្លាប់ ដោយបាន លើកលែងទោសអ្នកចង់សម្លាប់លោកមុនស្លាប់។ លោកបូជាចារ្យទាំងបីនេះ នៅភូមិភាគកំពង់ចាម ដែលសុខចិត្តរស់នៅ ជាមួយគ្រីស្តបរិស័ទមិនរត់ចោលស្រុក ទោះបីមានឱកាស ហើយក៏ដោយ។

នៅឆ្នាំ ១៩៧៥ គឺជាឆ្នាំ ដែលមានការផ្លាស់ប្តូររបប របស់ប្រទេសកម្ពុជាម្តងទៀតជាឆ្នាំដែល មានមរណសាក្សីជាច្រើនបានត្រូវ សម្លាប់នៅឆ្នាំនេះតែម្តង។ ក្រុមបព្វជិតាបេណេឌិកតាំង ៤ នាក់មាន លោកប៊ែរណា ឈឹម ឈុនសារ (Bernard Chim Chunsar,osb) ជាបូជាចារ្យបព្វជិត បាននាំយកសាមណេរ ២ នាក់ទៅជាមួយគឺ បងប្រុស អង់ដ្រេ រដ្ឋ រំជួរ (Andre Rath Romchour,osb) និងបងប្រុសដានី សេង និមិត្ត (Dany Seng Nimith, osb) ភៀសខ្លួនពីវត្តអារាមក្រុងកែបមកភ្នំពេញ។ លោកជួយ និងលើកទឹកចិត្តជនភៀសខ្លួនជាច្រើន។

ក្រោយពីខ្មែរក្រហម វាយយកក្រុងភ្នំពេញបាន ពួកគេត្រូវជម្លៀសទៅភូមិតាំងគោក រួមជាមួយគ្រីស្តបរិស័ទពីភូមិព្រះមាតា។

លោក និងបងប្រុស ចាកចេញទៅបាត់ដំបង ដោយមានប្រសាសន៍ថា "យើងត្រូវចែកផ្លូវគ្នា ដើម្បីស្វែងរកកូនចៀម យើងមិនអាចនៅផ្តុំគ្នាមួយកន្លែងដូច្នេះទេ..." តែលោកទាំងបី ត្រូវខ្មែរក្រហមចាប់ ហើយយកទៅសម្លាប់ នៅភូមិជុំ។

នៅបាត់ដំបង ពេលនោះមានលោកអភិបាល ទេព អ៊ីមសុត្ថា (Mgr.Tep Im Sotha) ដឹកនាំភូមិភាគ។

លោកសម្រេចចិត្ត ត្រឡប់ពីបារាំងមកស្រុកខ្មែរវិញ។ លោកលើកលែងទោស រួមឲ្យគ្រីស្តបរិស័ទ មុខបែកក្រុងបាត់ដំបង។

លោកបូជាចារ្យបព្វជិត សាល់ ប្រាដេ (Jean Badre) ដែលសុខចិត្តបន្តរស់នៅក្នុងស្រុកខ្មែរ ជួយព្យាបាលអ្នករបួសពីសង្គ្រាម ដោយមិនរើសបក្សពួក ។ លោកត្រូវខ្មែរក្រហម យកទៅសម្លាប់ជាមួយលោកអភិបាលទេព អ៊ីម នៅត្រង់ស្ពានយួន ផ្លូវទៅព្រំដែនថៃ។

នៅឆ្នាំនោះដែរ មានបងស្រីបព្វជិតាពីរនាក់ បានត្រូវសម្លាប់ គឺបងស្រីហ្សាក់ីរីន សួន (Jacaueline Soeun) ដែលចិញ្ចឹមកុមារកំព្រា។

បងស្រីចង់ ជួយកុមារទាំងនោះដោយភៀសខ្លួន ទៅវៀតណាម ប៉ុន្តែបងស្រី ត្រូវបញ្ជូន មកស្រុកខ្មែរវិញ ព្រោះបងស្រីជាខ្មែរ ហើយអ្នកដែលបញ្ជូនមកវិញ តែងតែត្រូវខ្មែរក្រហមសម្លាប់។

(នៅមានត)



# សម្ដេចប៉ាបៈ ការលើកលែងទោស របស់ព្រះជាម្ចាស់ គឺមិនមែនជាការកាត់ទោស ដោយតុលាការ



វិទ្យុវាទីកង់ កាលពីថ្ងៃទី៣១ ខែតុលា កន្លងទៅនេះ បានដកស្រង់ប្រសាសន៍ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ អំពីតួនាទីរបស់លោកបូជាចារ្យ និង មន្ត្រីអនុវត្តច្បាប់។

ប្រភពដដែល បានរាយការណ៍ថា នៅក្នុងអំឡុងពេល រៀបចំពិធីថ្វាយអភិបូជា នៅនិវេសនដ្ឋាន សានតា ម៉ាថា ជាភាសារអេស្ប៉ាញ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ជាបូជាចារ្យ គឺត្រូវដឹងអំពី ទំនាក់ទំនងរវាងជីវិត និងសង្គម ប៉ុន្តែបានរំលឹកថា ការលើកលែងទោស របស់ព្រះជាម្ចាស់ តាមរយៈបូជាចារ្យ គឺមិនដូច ជាការអនុវត្តច្បាប់ ដែលធ្វើដោយ មន្ត្រីអនុវត្តច្បាប់នោះទេ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានលើកឡើងថា ព្រះឫទ័យរបស់ព្រះជាម្ចាស់ជាការសន្ដោសប្រណី ចំពោះយើង គ្រប់គ្នាដែលជាមនុស្សជាតិទាំងអស់ នៅក្នុងនាមជាព្រះបិតា ដែលយកចិត្តទុកដាក់លើកូន ថែរក្សាកូន និងអប់រំកូន ដើម្បីអនាគតរបស់មនុស្សជាតិ ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តថា ព្រះយេស៊ូ បានព្យាបាលមនុស្ស ប៉ុន្តែព្រះអង្គមិនមែនជាគ្រូពេទ្យទេ។ ព្រះអង្គព្យាបាលមនុស្សតាមតែសញ្ញា ហើយសញ្ញានោះ គឺព្រះហឫទ័យរបស់ព្រះ-ជាម្ចាស់ដែលមកជួយមនុស្ស ។ ព្រះអង្គមានព្រះហឫទ័យ សន្ដោសយើងគ្រប់គ្នា ប៉ុន្តែ មិនដូចជាមន្ត្រីដែលអនុវត្តច្បាប់ ដែលអានសេចក្ដីសម្រេច ពឹងផ្អែកទៅលើភស្តុតាង ៕

# សម្ដេចប៉ាប ៖ ខ្ញុំចង់ឲ្យពិភពលោកគឺគ្មានភាពក្រីក្រ

នៅក្នុងបទសំភាសន៍ ជាមួយនឹងកាសែតហូឡង់មួយ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ភាពក្រីក្រ គឺជាប្រធានបទដ៏សំខាន់ និងជាវិញ្ញា-សារ នៃការអភិវឌ្ឍន៍មួយ ដែលគួរតែរិះគិត។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ពិភពលោកមួយដែលគ្មានភាពក្រីក្រ គឺជាសេចក្ដីស្រមៃ របស់សម្ដេច តាំងពីពេលដែល សម្ដេចនៅជាកុមារភាពនៅក្នុងប្រទេសអាហ្សង់ទីន។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា សម្ដេចស្អប់ភាពក្រីក្រ ជាកន្លែងដែល សម្ដេចមានប្រភពមកពី ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានឲ្យដឹងថា សម្ដេចបានធំធាត់នៅតាមផ្លូវ ដូច្នេះហើយបានជានៅពេលនេះ "ខ្ញុំចង់ឲ្យព្រះសហគមន៍ និងព្រះវិហារកាតូលិកទាំងអស់យកចិត្តទុកដាក់នឹង ការងារដែលពាក់ព័ន្ធនឹងភាពក្រីក្រ តាមបន្ទូលរបស់ព្រះយេស៊ូ "។

ព្រះសហគមន៍ និង ព្រះវិហារកាតូលិកទាំងអស់ គួររិះគិតគ្រប់កម្មវិធីគ្រប់ទង្វើ ដែលពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ ទោះបីជាទង្វើនេះតូចទាប និងសាមញ្ញក៏ដោយចុះ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ការធ្វើឲ្យពិភពលោកមួយគ្មានភាពក្រីក្រ គឺជារឿងលំបាក ប៉ុន្តែយើងត្រូវតែតស៊ូទាំងអស់គ្នា ហើយយកចិត្តទុកដាក់នៅលើសាមគ្គីភាព កុំអាត្មានិយម ៕

# សម្ដេចប៉ាបៈ ការលួចឯកសារគឺជាឧក្រិដ្ឋកម្ម

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃអាទិត្យកន្លងទៅនេះ បានថ្លែងអំពីករណីលួចឯកសារ របស់សន្តអសនៈ ដែលបានកើតមានឡើង កាលពីពេលថ្មីៗកន្លងទៅនេះ។

យោងទៅតាម សេចក្ដីរាយការណ៍ របស់វិទ្យុវ៉ាទីកង់ បានឲ្យដឹងថាការលេចធ្លាយ និងការលួចឯកសារសម្ងាត់របស់សន្តអសនៈ ឬបុរីវ៉ាទីកង់គឺ "បទឧក្រិដ្ឋមួយ" និងជា "ទង្វើអាក្រក់ ដែលថាមិនអាចជួយបាន"។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ នៅពេលជាមួយគ្នានោះ ក៏បានថ្លែងថា នេះជា "ព្រឹត្តិការណ៍ដ៏គួរឲ្យសោកស្ដាយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទង្វើរនេះគឺមិនអាចដាក់សំពាធដល់ រូបលោកនៅក្នុងការធ្វើកំណែទម្រង់ សន្តអសនៈក្រោមជំនួយពីទីប្រឹក្សា របស់លោកនោះបានទេ ។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា "ខ្ញុំបានដឹងថា អ្នកទាំងអស់គ្នាពិតជាមិនសប្បាយចិត្ត ឡើយចំពោះព័ត៌មានដែលបានចេញផ្សាយ កាលពីពេលថ្មីៗ អំពីការលេចធ្លាយឯកសារ សម្ងាត់របស់បុរីវ៉ាទីកង់ ដែលត្រូវបានគេលួចយកនឹងទៅផ្សព្វផ្សាយ។ ប៉ុន្តែខ្ញុំសូមឲ្យបងប្អូនគ្រីស្តបរិស័ទយល់ថា ទង្វើនេះគឺជាទង្វើឧក្រិដ្ឋកម្ម"។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា នេះគឺជាឯកសារ ដែលសម្ដេចខ្លួនឯងបានស្នើសុំទីប្រឹក្សារៀបចំសិក្សា ដើម្បីធ្វើកំណែទម្រង់ព្រះសហគមន៍ ហើយប្រកាសស្នើសុំឲ្យគ្រីស្តបរិស័ទ បន្តគាំទ្រកម្មវិធីកំណែទម្រង់ និង បន្តអធិដ្ឋានជាមួយនឹងសម្ដេចដើម្បីរិះគិត ឲ្យព្រះសហគមន៍ក្លាយជា កន្លែងដ៏វិសុទ្ធសម្រាប់មនុស្សទាំងអស់ ៕

# សន្តយ៉ូហាន

យ៉ូហាន ជាភាសាហេប្រឺ មានន័យថា " ព្រះជាម្ចាស់ប្រោសប្រទាន"។ លោកយ៉ូហានជាមិត្តសម្លាញ់ ដ៏ស្និទ្ធ-ស្នាលរបស់ព្រះយេស៊ូ ជាសាវ័ក ដែលព្រះយេស៊ូស្រឡាញ់។ លោកយ៉ូហានកើតនៅស្រុកយូដា។ បងប្រុសម្នាក់របស់គាត់ឈ្មោះយ៉ាកុប។ អ្នកទាំងពីររស់នៅតាមឆ្នេរបឹងទីបេរីយ៉ាដ នៅស្រុកកាលីឡេ មិនសូវឆ្ងាយប៉ុន្មានទេ ពីភូមិណាសារ៉ែត ដែលជាភូមិរបស់ព្រះយេស៊ូ។ ឪពុកលោកយ៉ូហាន និងលោកយ៉ាកុបឈ្មោះសេបេដេ ជាអ្នកនេសាទត្រី។ លោកយ៉ូហាន បានស្គាល់ព្រះយេស៊ូតាមរយៈលោក យ៉ូហានបាទីស្ត ដែលប្រាប់ថា គឺលោកនេះហើយ ដែលដកបាបចេញពីមនុស្សលោក។ លោកបានស្នាក់នៅផ្ទះជាមួយព្រះយេស៊ូមួយយប់។ ថ្ងៃមួយ ព្រះយេស៊ូត្រាស់ហៅគាត់ "សូមអញ្ជើញមកតាមខ្ញុំ"។ គាត់នឹងបងប្រុសបានទុកទូកចោល ហើយទៅតាមព្រះយេស៊ូទៅ។

លោកយ៉ូហាន បាននៅជាមួយព្រះយេស៊ូរហូត ដល់ព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង។ ក្នុងដំណើរជីវិតរបស់លោក ជាមួយព្រះយេស៊ូ លោកបានឃើញ ការអស្ចារ្យជាច្រើនដែលព្រះយេស៊ូបានធ្វើ។ ក្រោយពេលព្រះយេស៊ូសោយទិវង្គត និងមានព្រះ-ជន្មរស់ឡើងវិញ លោកយ៉ូហាន និងលោកសិលា ក្លាយជាសសរនៃព្រះសហគមន៍ គឺលោកទាំងពីរមានតួនាទីណែនាំគ្រីស្តបរិស័ទ ពង្រឹងជំនឿរបស់គេ និងប្រកាសដំណឹងល្អអំពីព្រះយេស៊ូដល់អស់អ្នកមិនទាន់ស្គាល់ព្រះអង្គ ។ ទៅយ៉ូហានទៅដល់ក្រុងអេភេសូ នៅប្រទេសទួរគី។ លោកសរសេរសៀវភៅដំណឹងល្អ សៀវភៅវិវរណៈ និងលិខិតបីច្បាប់ទៀតផ្ញើទៅគ្រីស្តបរិស័ទ ។ លោកតែងតែនិយាយថា "កូនចៅអើយ! ចូរស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង" ។




តាមគ្រីស្តបរិស័ទពីបុរាណ តំណាលថា លោកយ៉ូហាន ទទួលមរណភាព នៅអាយុ១០០ឆ្នាំ៕

# លោកបូជាចារ្យ តូតែត ផ្លាស់ការងារទៅសៀមរាប

លោកបូជាចារ្យតូតែត បាណែណាល់ បានផ្លាស់ប្ដូរមុខងារ ទទួលខុសត្រូវ ពីព្រះសហគមន៍បាត់ដំបង ទៅព្រះសហគមន៍តំបន់អង្គរខេត្តសៀមរាប វិញកាលពីថ្ងៃទី១៥ វិច្ឆិកាកន្លងទៅនេះ។

ទោះជាយ៉ាងណា លោកបូជាចារ្យ តូតែត នៅតែបន្តមុខងារជាតំណាងពេញសិទ្ធិរបស់ លោកអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង។

ព្រះសហគមន៍តំបន់អង្គរ មានព្រះសហគមន៍ ដូចជាព្រះសហគមន៍សៀមរាប ព្រះសហគមន៍ព្រែកទាល់ ព្រះសហគមន៍ចុងឃ្នាស ព្រះសហគមន៍តាអំ ព្រះសហគមន៍ពាក់ស្នែង និងព្រះសហគមន៍កំពង់ឃ្លាំង។ ការផ្លាស់ប្ដូរនេះ បានផ្ទេរលោកបូជាចារ្យស្ទេផានូស វីណាតូ ឲ្យទទួលខុសត្រូវនៅព្រះសហគមន៍បាត់ដំបងវិញ៕

# ព្រះសហគមន៍កាតូលិកពិនិត្យជម្ងឺភ្នែកជូនពលរដ្ឋដោយឥតគិតថ្លៃ


*ប្រជាពលរដ្ឋចូលមកពិនិត្យភ្នែកនៅព្រះសហគមន៍បាត់ដំបងពេទ្យឃាយជី*

ព្រះសហគមន៍កាតូលិក បាត់ដំបង បានរៀបចំកម្មវិធី ពិនិត្យសុខភាពភ្នែក ជូនដល់ប្រជាពលរដ្ឋ ក្នុងខេត្តបាត់ដំបង ដោយឥតបង់ប្រាក់ ពីថ្ងៃទី ២-៥ វិច្ឆិកា ដែលមានការសហការ ពីក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេស អេស្ប៉ាញ ចំនួន៤នាក់ ដោយពិនិត្យភ្នែក និងចែកជូនសម្ភារ។

លោកបូជាចារ្យម៉ានុច កុមារ ឯកាជាបូជាចារ្យ ទទួលខុសត្រូវលើកម្មវិធីពិនិត្យភ្នែកនេះ បានឲ្យដឹងថា រយៈពេល ២ថ្ងៃ គឺថ្ងៃទី២និងទី៣នេះ ក្រុមគ្រូពេទ្យទាំងនោះបានពិនិត្យភ្នែកជូនប្រជាពលរដ្ឋក្រីក្រ ជនចាស់ជរា កុមារ ជនពិការ និង សិស្សានុសិស្ស នៅក្នុងព្រះសហគមន៍បាត់ដំបង បានចំនួនជាង ១៥០ នាក់ ដែលក្នុងនោះមានការពិនិត្យភ្នែក ចែកថ្នាំ កាត់ និងចែកវ៉ែនតា ព្រមទាំងធ្វើការវះកាត់ធុនតូច ដោយបកភ្នែកឡើងបាយ ភ្នែកកន្ទុយថ្លែន ជូនប្រជាពលរដ្ឋដោយមិនគិតថ្លៃ។

នេះជាលើកទី៣ហើយ ដែលព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង ទទួលបាននូវកិច្ចសហការ ពីសំណាក់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសអេស្ប៉ាញ ក្នុងការពិនិត្យ និងចែកវ៉ែនតាជូនប្រជាពលរដ្ឋខ្មែរ នៅក្នុងខេត្តបាត់ដំបងនេះ ដែលធ្វើឡើងក្នុង១ឆ្នាំម្ដង។

លោកបូជាចារ្យម៉ានុច បានបន្ថែមថា សម្រាប់កិច្ចការនេះ បង្ហាញឲ្យឃើញនូវការចូលរួម របស់ព្រះសហគមន៍កាតូលិកនៅក្នុងកិច្ចការសង្គម តាមរយៈការសហការគ្នាពីសំណាក់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃប្រទេសអេស្ប៉ាញ និងព្រះសហគមន៍កាតូលិក នៅប្រទេសកម្ពុជា ដើម្បីជួយដល់ប្រជាពលរដ្ឋកម្ពុជាក្រីក្រ ដែលគ្មានលទ្ធភាពពិនិត្យសុខភាពភ្នែក នៅតាមមន្ទីរពេទ្យនានា។

កម្មវិធីពិនិត្យសុខភាពភ្នែកនេះ បានធ្វើឡើងរយៈពេល៤ថ្ងៃ ពីថ្ងៃទី ២-៥ វិច្ឆិកា នៅតាមតំបន់ព្រះសហគមន៍មួយចំនួន ដូចជាព្រះសហគមន៍បាត់ដំបងក្រុង(ពេទ្យឃាយជី) ព្រះសហគមន៍ទំពូង និងនៅព្រះសហគមន៍តាហែន៕

*ដោយឡុង សម្ផស្ស*

# យុវជនកំពង់គោផ្ដល់អំណោយដល់ចាស់ជរានិងអ្នកក្រីក្រ


*យុវជនកំពង់គោកំពុងផ្ដល់អំណោយដល់ចាស់ជរា។ រូបថតៈ រ៉ាវី*

ក្នុងឱកាស បុណ្យភ្ជុំបិណ្ឌប្រពៃណីខ្មែរ យុវជនយុវនារីនៅព្រះសហគមន៍កំពង់គោ បានប្រមូលថវិកាផ្ទាល់ខ្លួន ដើម្បីធ្វើទានជូនដល់ចាស់ជរា និងអ្នកក្រីក្រក្នុងភូមិកំណើតជាង២០គ្រួសារ។

លោក ពយ បូរ៉ែ ជាអ្នកផ្ដួចផ្ដើមគំនិតនេះបានឲ្យដឹងថា "នេះជាលើកទីមួយ ដែល យុវជនយុវនារីទាំងអស់ចាប់អារម្មណ៍ និងចង់ចូលរួមការធ្វើសកម្មភាពបែបនេះ"។ លោកបូរ៉ែបន្តថា អ្វីដែលសំខាន់នោះ គឺនៅក្នុងភូមិកំពង់គោក្រោម មានចាស់ជរា និងអ្នកក្រីក្រជាច្រើន ហើយអំណោយនេះ គឺជាការបង្ហាញសេចក្ដីស្រឡាញ់ ដែលយើងជាយុវជនមានចំពោះពួកគាត់។

លោកបូរ៉ែបន្តថា ទង្វើនេះ គឺឲ្យយុវជនយុវនារីទាំងអស់ ចេះចែករំលែកសេចក្ដីក្រលាញ់ ចេះសហការគ្នាជាក្រុម និង ចេះមើលឃើញពីទុក្ខលំបាករបស់អ្នកដទៃ។

កម្មវិធីចែកអំណោយ ដល់អ្នកភូមិនេះបានធ្វើឡើង កាលពីថ្ងៃទី១២ តុលា នៅឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមាន យុវជនយុវនារីប្រមាណជា២០នាក់ចូលរួម។

លោកតា ខៀវ រី ជាប្រធានភូមិក្នុងភូមិកំពង់គោក្រោម និងជាគ្រីស្តបរិស័ទ បានមានប្រសាសន៍ថា "វាជាសកម្មភាពមួយយ៉ាងល្អប្រសើរ ដែលចៅៗចេះចែករំលែក សេចក្ដីស្រលាញ់ចំពោះអ្នកដទៃ ជាពិសេសក្នុងពេលបុណ្យភ្ជុំបិណ្ឌនេះ បើទោះបីជារបស់មិនច្រើនតែទឹកចិត្តរបស់យើង គឺច្រើនជាងអ្វីៗទាំងអស់"។ លោកតារីបន្ថែមថា សូមឲ្យចៅៗ បន្តសកម្មភាពនេះជាបន្តទៀត ដើម្បី ជាគំរូដល់ក្មេងៗជំនាន់ក្រោយទៀត ហើយវាក៏ជាការធ្វើបុណ្យជាមួយនិងចាស់ៗក៏ដូចជាអ្នកក្រីក្រផងដែរ។

យុវជន-នារីទាំងអស់ បានដើរពីផ្ទះមួយទៅផ្ទះមួយដែលក្នុងនោះ មានទាំងគ្រួសារគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទផងដែរ ដែលមានចំនួន២៥គ្រួសារ ដែលបានទទួល អំណោយពីក្រុមយុវជនទាំងនេះ។ ក្នុងមួយគ្រួសារទទួលបាន មី ទឹកដោះគោ ទឹកក្រូច ស្ករស ក្រមាសារ៉ុង និងថវិកាចំនួន ១០០០០៛ ផងដែរ។

ថវិកាដែលយុវជន បានរៃអង្គាស មានចំនួនសរុបប្រមាណជា ៤៥០$ ដែលជាការចូលរួមពីយុវជនយុវនារីក្នុងភូមិ និងយុវជនដទៃទៀត៕

*ដោយស្រីម៉ាច*

# ឆ្នាំមហាករុណាទិគុណព្រះសហគមន៍ភូមិភាគភ្នំពេញបើកឲ្យមានបូជនីយចរ១១ខែ



*លោកអភិបាលអូលីវីយេធ្វើធម្មទេសនានៅព្រះសហគមន៍អរិយក្សត្រ។ កាលពីថ្ងៃទី១៥ វិច្ឆិកា ២០១៥។*

សម្រាប់ឆ្នាំ មហាករុណាទិគុណ សម្តែងព្រះហឫទ័យ មេត្តាករុណា សម្តេចប៉ាប សុំឲ្យគ្រប់ភូមិភាគ មានឱកាស ដើម្បីឲ្យគ្រីស្តបរិស័ទជួបជុំ ជំរះចិត្តគំនិត និងទទួលអនុគ្រោះពិសេសពីព្រះជាម្ចាស់។ នៅក្នុងឱកាសនេះដែរ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នឹងរៀបចំបូជនីយចរ សម្រាប់ព្រះសហគមន៍ និងការិយាល័យនានា ដែលមានទីតាំងនៅក្នុងភូមិភាគ ឲ្យចូលរួមផងដែរ។

លោកអភិបាលអូលីវីយេ ផ្មិតអីស្នែរ នៃព្រះសហគមន៍ កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍នៅថ្ងៃបុណ្យរំឭកខួប នៃការស្រង់រូបសំណាកព្រះនាងម៉ារី នៃទន្លេមេគង្គកាលពីថ្ងៃទី១៥ វិច្ឆិកាថា គម្រោងទីតាំង នៃបូជនីយចរ សម្រាប់ឆ្នាំមហាករុណាទិគុណសម្តែង ព្រះហឫទ័យមេត្តាករុណា របស់ព្រះជាម្ចាស់នេះព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានជ្រើសរើសទីតាំងបីកន្លែង គឺទី១នៅភ្នំពេញថ្មី ទី២គឺនៅព្រះសហគមន៍ផ្សារតូច និងទី៣គឺនៅព្រះសហគមន៍អរិយក្សត្រ។

លោកអភិបាលបន្តថា "យើងបានសម្រេចចិត្ត មាននៅភ្នំពេញថ្មី (ដែលអនាគតនឹងមានវិសាលវិហារ)។ ហើយបច្ចុប្បន្នខ្ញុំកំពុងសាងសង់ក្លោងទ្វារមួយជាសញ្ញាទ្វារដ៏វិសុទ្ធ ជាកន្លែងទីមួយសម្រាប់ឆ្លងធ្វើបូជនីយចររបស់យើង ពីភ្នំពេញថ្មី យើងធ្វើដំណើរទៅផ្សារតូច ដែលជាទីតាំងប្រវត្តិសាស្ត្រ នៃភូមិភាគភ្នំពេញ។ នៅផ្សារតូច ខ្ញុំរៀបចំកន្លែងមួយដើម្បីនឹកឃើញ ដល់មរណសាក្សីដែលជាសញ្ញាសម្គាល់ នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ យើងរៀបចំម៉្យាង(គឺ)កូនតាំងគោកមួយ។ បន្ទាប់មកគ្រីស្តបរិស័ទ បន្តបូជនីយចរទៅដល់អរិយក្សត្រ ដែលជាទីតាំងរបស់ម្ចាស់ក្សត្រី នៃសុខសន្តិភាព ដើម្បីឲ្យគ្រីស្តបរិស័ទ ពោពេញរួមជាមួយព្រះនាងម៉ារី អំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ដូច្នេះក្នុងមួយថ្ងៃ យើងអាចធ្វើដំណើរពីភ្នំពេញថ្មី ទៅផ្សារតូច ហើយមកទីនេះ(អរិយក្សត្រ) យើងថ្វាយអភិបូជា បញ្ចប់បូជនីយចររបស់យើង"។

លោកអភិបាល នឹងបើកជាផ្លូវការនូវបូជនីយចរនេះតាមកន្លែងនីមួយៗ គឺនៅភ្នំពេញថ្មី បើកថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១៥ រីឯផ្សារតូច គឺនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៥ និងនៅអរិយក្សត្រគឺនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦។ដំណើរបូជនីយចរ នៃភូមិភាគភ្នំពេញនឹងចាប់ផ្តើមពីថ្ងៃទី១ ខែមករា ដល់ខែ វិច្ឆិកា ឆ្នាំ ២០១៦៕

*ដោយកល្បព្រឹក្ស*

# ព្រះសហគមន៍កាតូលិកកោះរកាចូលរួមអបអរពិធីបុណ្យសំដែងជំនឿជាមួយនឹង សហគមន៍មូលដ្ឋាន

ពិធីបណ្តែតប្រទីប គឺជាផ្នែកមួយ នៃពិធីដែលរៀបចំឡើងនៅក្នុងពេលចេញវស្សា ដោយពុទ្ធសាសនិកជន ប៉ុន្តែកាលពីពេលថ្មីៗនេះ គ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍កាតូលិក កោះរកាក៏បានប្រារព្ធពិធីបុណ្យជាប្រពៃណី នេះផងដែរ។

លោកបូជាចារ្យ ផាន បូរី ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កាតូលិកកោះរកា បានមានប្រសាសន៍ថា បណ្តែតប្រទីប គឺជាពិធីបុរាណកាលមួយរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានដោយជាទូទៅ ពួកគេបានប្រារព្ធពិធីនេះតាមជំនឿ របស់ព្រះពុទ្ធសាសនា ប៉ុន្តែ ការរៀបចំពិធីនេះ កាលពីរាត្រីថ្ងៃទី២៧តុលា គឺគ្រីស្តបរិស័ទយើងរៀបចំតាមជំនឿរបស់យើង ប៉ុន្តែយើងបាន ចូលរួមបណ្តែតប្រទីបផ្ទាល់របស់ពួកយើងរួមជាមួយនឹងពួកគេ ។

កម្មវិធីបណ្តែតប្រទីបនេះ គឺព្រះសហគមន៍កាតូលិកកោះរកា តែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដោយមានការរៀបចំអធិដ្ឋានតេហ្សេ ជាមួយគ្រីស្តបរិស័ទចំនួនមួយម៉ោង និងមានសរសេរពាក្យ អធិដ្ឋានផ្ទាល់ខ្លួនដាក់ចូលទៅក្នុងប្រទីប ដែលបានរៀបចំតែមួយ យ៉ាងប្រណិតលម្អដោយសញ្ញាឈើឆ្កាងជាប់ជាមួយផង ដើម្បីបណ្តែតទៅតាមទឹកទន្លេមួយកន្លែង នៅក្នុងតំបន់កោះរកានោះ រួមជាមួយនឹងសហគមន៍ទាំងមូល។

លោកបូជាចារ្យ បានមានប្រសាសន៍ឲ្យដឹងទៀតថា "ការដែលមានកម្មវិធីបណ្តែតប្រទីបនេះ ត្រូវបានរៀបចំឡើងគឺដោយសារតែគ្រីស្តបរិស័ទចង់ចូលរួមកម្មវិធីនេះជាមួយអ្នកភូមិ ចង់ចូលរួមអំណរសប្បាយ ដោយភាពអ៊ូអរជាមួយគ្នា តែនៅក្នុងនោះ យើងក៏មិនបានភ្លេចនូវអត្តសញ្ញាណរបស់ខ្លួនថា យើងជានរណា?យើងធ្វើដើម្បីអ្វី?" ។

លោកបូចារ្យ បានបន្ថែមថា វាជាពេលវេលាមួយយ៉ាងល្អ ដែលឲ្យយើងមកជួបជុំគ្នា ដើម្បីអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ នូវអំណោយទានទាំងឡាយ ទាំងផលល្អ និងផលអាក្រក់ក្នុងរយៈពេល ពេញមួយឆ្នាំ កុំអោយយើងវង្វេង ជំនឿ បើទោះបីជាកម្មវិធីសម្រាប់ពុទ្ធសាសនាមែន តែយើងជាកាតូលិកក៏អាចធ្វើបាន ដោយយើងមានព្រះជាម្ចាស់ជាប្រមុខ។ លើសពីនេះទៅទៀតលោកបូជាចារ្យរូបនេះបន្តទៀតថា ៖ តាមពុទ្ធបរិស័ទ គឺមានដាក់បាយ នំចំណី ជាសំណែន ដាក់ចូលទៅក្នុងប្រទីបដើម្បីបណ្តែតទៅតាមជំនឿរបស់គេ តែចំពោះយើងវិញ គឺយើងបានដាក់នូវពាក្យអធិដ្ឋានជាច្រើន ដែលចេញពីចិត្តរបស់យើង ដាក់ចូលទៅក្នុងប្រទីបដើម្បីបណ្តែត ដោយសេចក្តីសង្ឃឹមថាបានផ្ញើរសេចក្តីទុក្ខលំបាក និងអំណរសប្បាយទាំងអស់ទៅព្រះជាម្ចាស់ តាមរយៈប្រទីប ដែលយើងបានបណ្តែតទៅ។

កម្មវិធីនេះ បានប្រព្រឹត្តទៅយ៉ាងសប្បាយរីករាយ ដោយគ្រីស្តបរិស័ទ និងពុទ្ធសាសនិក កាន់គោម ឬប្រទីបរៀងៗខ្លួន ខ្លះជាសហគមន៍ ដើម្បីបណ្តែតទៅលើទឹក បណ្តាលឲ្យមានពន្លឺភ្លឺចញ្ចែងជញ្ចាច នៃពន្លឺភ្លើងទានទៅលើផ្ទៃទឹកទន្លេ ក្នុងភូមិកោះរកាគួរឲ្យទាក់ទាញ។

ព្រះសហគមន៍កាតូលិក កោះរកាគឺមានទីតាំងស្ថិតនៅក្នុងភូមិកោះរកាក្រៅ ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយគ្រីស្តបរិស័ទដែលបានចូលរួមពិធីបណ្តែតប្រទីបនេះ គឺមានប្រមាណជា ៦០នាក់៕

*ដោយរឿន ស្រីម៉ាច*

# បូជនីយេស៍រិះគិតអំពីអគ្គសញ្ញាលើកលែងទោស

ព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ រួមសហការជាមួយការិយាល័យយុវន ជំទង់ និងកុមារបានរៀបចំធ្វើបូជនកិច្ច ដោយថ្មើរជើង រិះគិតពីអត្ថន័យ នៃអគ្គសញ្ញាលើកលែងទោស ដែលមានអ្នកចូលរួមចំនួន ២៣០នាក់ ក្នុងរយៈចម្ងាយ ២១គីឡូម៉ែត្រ ពីព្រះសហគមន៍ផ្លូវត្រី តាមដងទន្លេមេគង្គ មកព្រះសហគមន៍អរិយ្យក្សត្រ កាលពីថ្ងៃទី ២៤ដល់ ២៥ តុលាកន្លងទៅ។



គ្រីស្តបរិស័ទធ្វើដំណើរពីផ្លូវត្រីទៅកាន់អរិយក្សត្រ។

កម្មវិធីរយៈពេល ២ថ្ងៃនេះបូជនី-យេសក៍ទាំងអស់ បានទទួលការអប់រំពីលោកអភិបាល ព្រះសហគមន៍ភូមិភាគភ្នំពេញអូលីវីយេ ឆ្មឹតអីស្លេ អំពីអគ្គសញ្ញាលើកលែងទោស។

លោកអភិបាល បានណែនាំគ្រីស្តបរិស័ទទាំងអស់ថា យើងជាមនុស្សមានបាប និងជួនកាលយើងដើរខុសផ្លូវតែព្រះជាម្ចាស់ មានព្រះហឫទ័យអាណិតមេត្តា និងសុខចិត្តទុកពេលវេលាឲ្យយើងម្នាក់ៗកែប្រែចិត្តគំនិត។ លោកអភិបាលបានសំណូមពរ ឲ្យគ្រីស្តបរិស័ទទាំងអស់ឲ្យកែប្រែចិត្តគំនិត ដែលនាំឲ្យមានជីវិតថ្មី រួមជាមួយព្រះជាម្ចាស់ គឺមានន័យថា ជាមិត្តសម្លាញ់ជិតស្និទ្ធរបស់ព្រះយេស៊ូ។

គ្រីស្តបរិស័ទ ដែលចូលរួមបូជនកិច្ចនេះ មានអ្នកខ្លះបានដើរដោយស្បៀមស្ងាត់ និងអ្នកខ្លះទៀតសូត្រធ្មំ ដើម្បីអធិដ្ឋាន និងរិះគិតអំពីការលើកលែងទោសរបស់ព្រះជាម្ចាស់។

លោក សុខ ធឿន ជាបូជនីយេស៍មួយរូបនិយាយថា នេះជានិមិត្តរូបមួយក្នុងដំណើរជីវិតរបស់គាត់ដើម្បីដើរតាមព្រះយេស៊ូ ដោយមានទាំងការហត់នឿយ លំបាក និងមានបញ្ហាតាមផ្លូវមួយចំនួនផងដែរ។ លោកសុខ ធឿន បានបន្តថា "ព្រះជាម្ចាស់បានជួយខ្ញុំឲ្យដើរទៅមុខ ដោយពឹងផ្អែកទៅលើព្រះយេស៊ូ និងក្នុងពេលដែលមានអំណរសប្បាយ (ខ្ញុំ)ក៏សូមអរព្រះគុណព្រះជាម្ចាស់ ដែលព្រះអង្គនៅជាមួយខ្ញុំគ្រប់ពេលវេលា"៕ *ដោយដាលីស*

# ទេវវិទ្យាល័យមាននិស្សិត៣នាក់បន្ថែម



*និស្សិតទេវវិទ្យាល័យក្នុងឆ្នាំ២០១៥*

ក្នុងឆ្នាំសិក្សាថ្មីនេះ ទេវវិទ្យាល័យសន្តយ៉ូហាន ម៉ារី វីយ៉ាណែរ នាទីក្រុងភ្នំពេញ បានទទួលនិស្សិតថ្មី ចំនួន៣នាក់បន្ថែមទៀត កាលពីថ្ងៃទី២១ តុលា ២០១៥នេះ។

ទេវវិទ្យាល័យ គឺជាសាលាបណ្តុះបណ្តាលយុវជនកាតូលិក ដែលមានបំណងចង់ថ្វាយខ្លួន បម្រើព្រះជាម្ចាស់ជាបូជាចារ្យកាតូលិក ដែលរស់នៅលីវអស់មួយជីវិត និង ស្ម័គ្រចិត្តបម្រើព្រះសហគមន៍កាតូលិក។

ក្នុងឆ្នាំសិក្សាថ្មីនេះ មានយុវជនចំនួន៣នាក់ទៀត ដែលបានសុំការអនុញ្ញាតពីលោកអភិបាល ដើម្បីចូលសិក្សានៅទេវវិទ្យាល័យ គឺមាន២នាក់មកពី មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង និងម្នាក់មកពីមណ្ឌលសកម្មភាពទន្លេមេគង្គ។

លោក វី សំណាង បេក្ខជនថ្មី បានឲ្យដឹងថា រយៈពេលជាង៧ឆ្នាំ លោកបានរិះគិតយ៉ាងច្រើនអំពីជីវិតជាបូជាចារ្យ។ លោកបន្តថា ការសម្រេចចិត្តចូលក្នុងទេវវិទ្យាល័យ ព្រោះយល់ឃើញថា ព្រះសហគមន៍នៅប្រទេសកម្ពុជា ត្រូវការអ្នកថែរក្សា...។ លោកសង្ឃឹមថា លោកនឹងទទួលបានបទពិសោធន៍យ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ និងអាចប្រកាសដំណឹងល្អ ឲ្យបងប្អូនឯទៀតៗស្គាល់ព្រះយេស៊ូដែរ។

ក្នុងកម្មវិធីទទួលនិស្សិតថ្មី និងបើកបវេសនកាលនេះ លោកអភិបាល អូលីវីយេ ឆ្មឹតអីស្លែរ នៃព្រះសហគមន៍ភូមិភាគភ្នំពេញបានមានប្រសាសន៍ ទៅកាន់និស្សិតទាំងអស់ថា ទេវវិទ្យាល័យគឺជាកន្លែងមួយ ដើម្បីទទួលការអប់រំពីព្រះយេស៊ូផ្ទាល់ ដែលណែនាំឲ្យទៅជាអ្នកបម្រើព្រះបិតា និង បងប្អូនឯទៀតៗ។ ហើយក៏ជាកន្លែង ដើម្បីរស់នៅ ក្រោមការដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបំភ្លឺយើងទាំងការអធិដ្ឋាន រៀន និងពេលយើងមានជីវិតជាក្រុម ដើម្បីឲ្យជីវិត ចិត្ត គំនិត និងបេះដូងរបស់យើងស្របតាមព្រះយេស៊ូ ដែលជាគង្វាលដ៏សប្បុរស និងជាអ្នកបម្រើដែលទទួលទុក្ខលំបាកជាច្រើន ។ លោកអភិបាលមានប្រសាសន៍ទៀតថា និស្សិតទាំងអស់គឺ នៅទេវវិទ្យាល័យ ដើម្បីដើរតាមព្រះយេស៊ូ ដូចក្រុមគ្រីស្តទូតពីដើម ដែលរស់នៅ និងយកចិត្តទុកដាក់ស្តាប់ ហើយដើរតាមព្រះយេស៊ូ។ លោកអភិបាលបានសរុបថា ទាំងនេះគឺដើម្បីឲ្យយើងទៅជាបូជាចារ្យនៅក្នុងព្រះសហគមន៍ ដោយចេះបម្រើ។

លោកបប់ ពិសេ ជានាយកទេវ-វិទ្យាល័យបានឲ្យដឹងថា ឆ្នាំនេះមាន៣នាក់ថ្មី គឺបង្ហាញថា ព្រះជាម្ចាស់បានឆ្លើយទៅនឹងការអធិដ្ឋាន ដែលព្រះសហគមន៍ បានរៀបចំជារៀងរាល់ខែ។ លោកបន្តថា នេះជាសញ្ញាមួយដ៏ល្អដែលលើកទឹកចិត្ត និងជំរុញឲ្យយើងទៅមុខទៀត ជាពិសេសគឺជារឿងល្អសម្រាប់ព្រះសហគមន៍កម្ពុជា ព្រោះនឹងមាន បូជាចារ្យដែលចេញពីទឹកដីកម្ពុជាផ្ទាល់។

និស្សិតទេវវិទ្យាល័យ សន្តយ៉ូហានម៉ារីវីយ៉ាណែរ មាននិស្សិតសរុបទាំងអស់ចំនួន៩នាក់។ ក្នុងខែវិច្ឆិកានេះ មានលោកសែ សាត ទទួលការតែងតាំងជាឧបដ្ឋាក។ ហើយក្នុងឆ្នាំ ២០១៤ និង២០១៥នេះព្រះសហគមន៍កាតូលិកកម្ពុជាបានមាននិស្សិតទេវវិទ្យាល័យ គឺលោកផាន បូរី និងលោកមួង រស់ បានទទួលអគ្គសញ្ញាតែងតាំង ជាបូជាចារ្យកាតូលិក។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន មានសាសនទូត និងបព្វជិតប្រមាណជាង ១៥០នាក់ ដែលកំពុងបំពេញការងារប្រកាសដំណឹងល្អ តែមានបូជាចារ្យជាតិខ្មែរតែ៧នាក់ប៉ុណ្ណោះ៕

# លោកគីគេ ហ្វីការេដូ
# អភិបាលព្រះសហគមន៍ កាតូលិកភូមិភាគបាត់ដំបង



## តំបន់បាត់ដំបង និងប៉ៃលិន



លោកបូជាចារ្យ ស្ទេផានូស វីណាតូ
ទទួលខុសត្រូវព្រះសហគមន៍
បាត់ដំបងក្រុង និងប៉ៃលិន



លោកអភិបាលគីគេ ហ្វីការេដូ
ទទួលខុសត្រូវព្រះសហគមន៍តាហែន



លោកបូជាចារ្យពេត្រូ ហ្គោមែស៍
ទទួលខុសត្រូវព្រះសហគមន៍
ច្រាបវាល



លោកបូជាចារ្យឯការ ម៉ានុច កុមារ
ទទួលខុសត្រូវ
ព្រះសហគមន៍និគម



លោកបូជាចារ្យទម្លាប់ សុផល
ទទួលខុសត្រូវ
ព្រះសហគមន៍ទំពូង និងខ្នាចរមាស



លោកបូជាចារ្យមួង រស់
ទទួលខុសត្រូវព្រះសហគមន៍ស្ទឹង

## តំបន់ទន្លេ



លោកបូជាចារ្យ លីឃ្យុង យុងចន
ទទួលខុសត្រូវព្រះសហគមន៍ពោធិ៍សាត់
ផ្នូកទ្រូ កំពង់ហ្លួង កំពង់ឆ្នាំង

## តំបន់កំពង់ធំ



លោកបូជាចារ្យ បាកជីន ហ្សក់ពីយ៉ូ
ទទួលខុសត្រូវព្រះសហគមន៍
តំបន់កំពង់ធំ



លោកបូជាចារ្យ បុង បុង
បូជាចារ្យជំនួយ

## តំបន់អង្គរ



លោកបូជាចារ្យ តូតែត បាណេណាល់
ទទួលខុសត្រូវព្រះសហគមន៍សៀមរាប
ចុងឃ្នៀស តាអំ ព្រែកទ័ល កំពង់ឃ្លាំង



លោកបូជាចារ្យ ហ្វ្រេដចហ្គោរីអូស ព្រីយ៉ាឌី
ទទួលខុសត្រូវព្រះសហគមន៍
ស្វាយស៊ីសុផុន និងប៉ោយប៉ែត



លោកបូជាចារ្យ ផុងផាន ភោគថាវី
ទទួលខុសត្រូវព្រះសហគមន៍
ឧត្តរមានជ័យ និងព្រះវិហារ



លោកបូជាចារ្យ ម៉ាក ឡូប៉េ
ជំនួយការបូជាចារ្យ



លោកបូជាចារ្យពេត្រូ ហ្គោមែស៍
ទទួលខុសត្រូវព្រះសហគមន៍ចំណោម

# ពិធីតែងតាំងលោកស្ទេផាន សែ សាត ជាឧបដ្ឋាក



*រូបថតៈ វ៉ាន់ សម្បត្តិ*

មនុស្សប្រមាណជិត ១០០០នាក់ បានមកជួបជុំគ្នា ក្នុងព្រះវិហារគ្រួសារដ៏វិសុទ្ធ នៃព្រះសហគមន៍កាតូលិក អ្នកលឿង ដើម្បីចូលរួមអបអរសាទចំពោះការតែងតាំងលោក ស្ទេផាន សែ សាត ជាឧបដ្ឋាក ដែលធ្វើឡើងកាលពីថ្ងៃទី ១៤ វិច្ឆិកា ២០១៥ កន្លងទៅ ក្រោមអធិបតីភាព របស់លោកអភិបាលទាំងបីភូមិភាគ រួមនិងលោកបូជាចារ្យជាច្រើនរូបទៀត។

លោកនាយក ទេវវិទ្យាល័យកម្ពុជា លោកបូជាចារ្យ បប់ ពិសេ នៅមុខព្រះសហគមន៍ បានស្នើសុំ លោកអភិបាលអូលីវីយេ ជាផ្លូវការ សុំអនុញ្ញាតឲ្យលោក ស្ទេផាន សែ សាត បានទទួលការតែងតាំងជាឧបដ្ឋាក ដោយលោកបានបញ្ជាក់ថា បេក្ខជនរូបនេះ ពិតជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើជាឧបដ្ឋាកពិតមែន។

ក្នុងកម្មវិធីនេះដែរ លោកបូជាចារ្យ សេរ៉ាល់ រ៉ូសាំង ជាអ្នកណែនាំជីវិតខាងផ្លូវវិញ្ញាណរបស់ឧបដ្ឋាកសែ សាត បានផ្តល់សក្ខីភាព យ៉ាងនេះថា លោកស្ទេផាន សែ សាត បានយកចិត្តទុកដាក់ក្នុងគ្រប់កិច្ចការ និងការសិក្សាជាពិសេសតាមរយៈ ការបម្រើព្រះសហគមន៍ ដោយចូលរួមជាមួយក្រុមយុវជន និងកុមារ សម្រាប់ភូមិភាគកំពង់ចាម ។ លោកបូជាចារ្យសេរ៉ាល់ យល់ឃើញថា ជំនឿ និងការត្រាស់ហៅរបស់ព្រះ-ជាម្ចាស់ចំពោះលោកសាត គឺដើរទន្ទឹមគ្នា ព្រោះគាត់មានផ្លូវវិញ្ញាណយ៉ាងស៊ីជម្រៅ និងរបៀបរស់នៅបែបក្រីក្រសាមញ្ញ មិនតែប៉ុណ្ណោះ លោកសាតជាមនុស្សស្មោះត្រង់ គ្រប់កិច្ចការទាំងថវិកា និងការសិក្សា ជាពិសេសគាត់មានចិត្តស្រឡាញ់ព្រះសហគមន៍ និងបងប្អូនទាំងអស់ ហើយជាមនុស្សសកម្មខាងផ្នែកជំនឿ។

ក្រោយពីការប្រកាសនេះ លោកអភិបាល បានសុំឲ្យបេក្ខជន ប្រកាសពាក្យសច្ចារបស់ខ្លួន នៅចំពោះមុខព្រះសហគមន៍ទាំងមូល ដោយរស់នៅលីវអស់មួយជីវិត ស្តាប់បង្គាប់លោកអភិបាល ដាក់ខ្លួនជាអ្នកក្រីក្រ។ លោកឧបដ្ឋាក ត្រូវបានបំពាក់កន្សែងឆៀង និងទទួលព្រះគម្ពីរ ជាសញ្ញានៃការបំពេញបេសកម្មប្រកាសព្រះបន្ទូល ជឿលើព្រះបន្ទូល និងរស់នៅស្របតាមសេចក្តី ដែលព្រះយេស៊ូបានប្រៀនប្រដៅ។

ឧបដ្ឋាក គឺជាជំហានចុងក្រោយ មុនពេលទទួល ពិធីតែងតាំងជាបូជាចារ្យកាតូលិក។ លោកឧបដ្ឋាក គឺជាមុខងារមួយក្នុងការបម្រើព្រះសហគមន៍ ដែលមានតួនាទីបម្រើពិធីបុណ្យ ធ្វើអគ្គសញ្ញាជ្រមុជទឹក អគ្គសញ្ញាអាពាហ៍ពិពាហ៍ លាបប្រេងឲ្យអ្នកជំងឺ ចែកព្រះកាយជាដើម។

លោកអភិបាលអូលីវីយេ ជ្មីតអីស្លែរ នៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា ជីវិតជាឧបដ្ឋាក គឺបម្រើនៅក្នុងអភិបូជា និងមប្រើនៅក្នុងជីវិតរបស់គេផ្ទាល់ ដោយបង្ហាញពីព្រះយេស៊ូ។ លោកអភិបាលអូលីវីយេ បានផ្តាំផ្ញើដល់លោកឧបដ្ឋាកថ្មី និងបងប្អូនទាំងអស់ ឲ្យថែរក្សាការត្រាស់ហៅ ដោយភ្ញាក់ស្មារតី ស្តាប់ព្រះសូរសៀងព្រះជាម្ចាស់ ជាពិសេសចំពោះយុវជនយុវនារី។ លោកក៏អំពាវ-នាវ សុំឲ្យបងប្អូនគ្រីស្តបរិស័ទទាំងអស់នៃព្រះសហគមន៍ ក្នុងប្រទេសកម្ពុជា យកចិត្តទុកដាក់អធិដ្ឋាន លើកទឹកចិត្ត និងថៃរក្សាយុវជនយុវនារី ដែលមានបំណងចង់បួស។

លោកឧបដ្ឋាកស្ទេផាន សែ សាត មានបងប្អូន៥នាក់ ជាកូនច្បងមកពីក្រុមគ្រួសារពុទ្ធបរិស័ទ ក្នុងខេត្តត្បូងឃ្មុំ។

លោកឧបដ្ឋាក ស្ទេផាន សែ សាត មានប្រសាសន៍ដែរថា "សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំចង់ពពោះដូចព្រះនាងម៉ារី ក្រោយមកប្រសូតព្រះបន្ទូលរបស់ព្រះអង្គ គឺប្រកាសដំណឹងល្អ បន្តជំនឿរបស់ខ្លួន ហើយជាពិសេស គឺនាំភាពដ៏វិសុទ្ធរបស់ព្រះអង្គទៅដល់បងប្អូន"។

លោកឧបដ្ឋាក បានបន្ថែមថាអំ-ណោយទាន ដែលលោកបានទទួលកន្លងមក គឺបានពីព្រះជាម្ចាស់ "ទោះបីជាពេលខ្លះលំបាក វង្វេងតិចៗ តែខ្ញុំទុកចិត្តលើព្រះជាម្ចាស់"។

លោកអភិបាល អន់តូនីសាមី ស្វូសៃរាជ្យ នៃព្រះសហគមន៍កាតូលិក កំពង់ចាម មានប្រសាសន៍ឲ្យដឹងថា "បងប្រុសសាត ជាមនុស្សមានចិត្តសុភាព និងពូកែរិះគិតឆ្លើយសំណួរ... មានយោបល់ល្អ។ ខ្ញុំសប្បាយចិត្ត ថ្ងៃនេះ ដោយសារការតែងតាំងជាឧបដ្ឋាក វាស៊ីគ្នា នឹងអំណោយទានរបស់គាត់... គាត់ចេះប្រើរឿងខ្លី ដែលទាក់ទងនឹងជីវិតពិតក្នុងធម្មទេសនា មកបង្រៀនគ្រីស្តបរិស័ទ ដែលធ្វើឲ្យគេយល់ និងដឹងច្បាស់ថា អ្វីដែលគាត់និយាយចេញពីជម្រៅចិត្តរបស់គាត់។នេះជាសមត្ថភាពពិសេសរបស់គាត់"។

លោកអភិបាលអន់តូនីសាមី បន្ថែមថា លោកមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងលើឧបដ្ឋាកថ្មីរូបនេះ។ លោកអភិបាល "បងប្រុសសាត មួយឆ្នាំទៀតគាត់តែងតាំងជាបូជាចារ្យ គាត់នឹងមានបទ-ពិសោធច្រើនពីឥឡូវទៅ (នឹង)ក្លាយជាទ្រព្យសម្បត្តិក្នុងជីវិតរបស់គាត់ ។ ហើយខ្ញុំសូមអរគុណបងប្អូន ដែលបានចូលរួមពិធីនេះ ហើយសូមបន្តអធិដ្ឋានសម្រាប់គាត់ដើម្បីបន្តទៅមុខទៀត"។

ក្រោយពីទទួល ការតែងតាំងនេះ លោកឧបដ្ឋាកថ្មី ត្រូវបានទទួលភារកិច្ចពីអភិបាលភូមិភាគកំពង់ចាម ដើម្បីបម្រើព្រះសហគមន៍ នៃតំបន់អ្នកលឿង នៃភូមិភាគកំពង់ចាម រយៈពេលមួយឆ្នាំ រហូតដល់ពេលលោក ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនាឆ្នាំក្រោយ។

ក្នុងឆ្នាំ២០១៤ និង២០១៥នេះ ព្រះសហគមន៍កាតូលិកកម្ពុជា មានលោកបូជាចារ្យ ជាតិខ្មែរចំនួន៣រូប ត្រូវបានតែងតាំង ក្នុងនោះរួមមានលោកផាន បូរី លោកមួង រស់ និងលោកសុខណា។ ព្រះសហគមន៍កាតូលិកកម្ពុជា បច្ចុប្បន្ន មានបូជាចារ្យជាតិខ្មែរចំនួន ៨នាក់ប៉ុណ្ណោះ ៕

*ដោយដាលីស*





លោកបូជាចារ្យ ផាន បូរី

**១ វិច្ឆិកា៖ (អាទិត្យទី៣១ ក្នុងរដូវធម្មតា) មក១២,២៨-៣៤**

*" ចូរស្រឡាញ់ព្រះជាម្ចាស់ ! ចូរស្រឡាញ់បងប្អូនឯទៀត ឱ្យដូចស្រឡាញ់ខ្លួនឯង"*

ព្រះយេស៊ូភ្ជាប់ធម្មវិន័យ ដែលនាំឱ្យមានសេចក្តីស្រឡាញ់ មិនគ្រាន់តែអង្គុយក្នុងព្រះវិហារ សូត្រធម៌ប៉ុណ្ណោះទេ គឺត្រូវបង្ហាញធម៌មេត្តាករុណាដល់គ្នាទៅវិញទៅមក គឺស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់បងប្អូនដូចមានក្នុងធម៌វិន័យរបស់ព្រះយេស៊ូ ដែលនាំឱ្យអ្នកជឿមានសេចក្តីស្រឡាញ់កាន់តែខ្លាំងឡើងៗ ។

ព្រះជាម្ចាស់ ស្រឡាញ់អ្នកជឿដូចស្វាមីស្រឡាញ់ភរិយា។ អ្នកជឿត្រូវតែស្រឡាញ់ព្រះអង្គ ដោយស្មោះអស់ពីកំលាំងកាយ កំលាំងចិត្ត ដូចភរិយាស្រឡាញ់ស្វាមីយ៉ាងនោះដែរ មានន័យថា រួមរស់រួមស្លាប់ គោរពកោតខ្លាចព្រះអង្គ យើងមានសេចក្តី ស្រឡាញ់ ព្រោះព្រះអង្គស្រឡាញ់យើងជាមុន ។

គ្រីស្តបរិស័ទត្រូវមានករវែង ដូចសត្វមួយប្រភេទដែលមានករវែង គឺគ្រីស្ត-បរិស័ទមានចក្ខុវែងឆ្ងាយ មានចិត្តធំក្នុងការបង្ហាញសេចក្តីស្រឡាញ់ មិនតែប៉ុណ្ណោះ គឺមានចិត្តធំក្នុងការចែកសេចក្តីស្រឡាញ់ គឺសេចក្តីស្រឡាញ់ហូរមកពីបេះដូងព្រះយេស៊ូ។

ហេតុនេះ ចូរបងប្អូនបន្ទាបខ្លួនរៀនស្រឡាញ់ដូចព្រះអង្គបានបង្រៀនថា៖ "ចូរស្រឡាញ់ព្រះជាម្ចាស់ ! ចូរស្រឡាញ់បងប្អូនឯទៀតៗ ឱ្យដូចស្រឡាញ់ខ្លួនឯង"។

**៨ វិច្ឆិកា៖ (អាទិត្យទី៣២ ក្នុងរដូវធម្មតា) មក១២,៣៨-៤៤**

ជឿលើព្រះយេស៊ូ មិនគ្រាន់តែបង្ហាញសំបកខាងក្រៅថា ខ្ញុំស្រឡាញ់ព្រះអង្គប៉ុណ្ណោះទេ គឺប្រព្រឹត្តទាំងចិត្តទាំងកាយឱ្យស្របគ្នា គឺកុំធ្វើដូចពួកបណ្ឌិតខាងវិន័យ ដាក់ជាយអាវកាន់តែវែងទៅៗ ដើម្បីបង្ហាញថាពួកគេ ជាអ្នកកាន់សាសនាដ៏ត្រឹមត្រូវ ព្រមទាំងចង់ឱ្យគេកោតសរសើរថែមទៀតផង ផ្ទុយទៅវិញព្រះយេស៊ូ សូមឱ្យគេចេះបើកភ្នែកមើលអ្នកក្រីក្រ ដូចជាស្ត្រីមេម៉ាយ ក្មេងកំព្រាអ្នកគ្មានទីពឹង ។

ព្រះអង្គ សូមឱ្យយើងចេះបើកចិត្តទទួលព្រះបន្ទូលព្រះអង្គ ដោយមានជំនឿ មានសេចក្តីសង្ឃឹម មានសេចក្តីស្រឡាញ់ និងទុកឱ្យព្រះអង្គ ច្នៃជីវិតរបស់យើងតាមរបៀបត្រឹមត្រូវ គឺរស់ជាគ្រីស្តបរិស័ទល្អ ចេះជួយគ្នា មានសីលធម៌ ចេះលើកលែងទោសឱ្យគ្នា។

**១៥ វិច្ឆិកា៖ (អាទិត្យទី៣៣ ក្នុងរដូវធម្មតា) មក១៣,២៤-៣២**

មុនពេលព្រះយេស៊ូ សោយព្រះទិវង្គត ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កអំពីពេលអនាគត។ ព្រះអង្គសូមឱ្យអ្នកជឿទាំងអស់ ប្រុងស្មារតីរង់ចាំទទួលព្រះអង្គ ដោយរាក់ទាក់ស្មោះអស់ពីចិត្ត ដ្បិតយើងមិនដឹងថាព្រះអង្គនឹងយាងមកថ្ងៃណា ខែណា ឆ្នាំណាទេ គឺព្រះអង្គនឹងយាងមក ក្នុងអំឡុងពេលដែលយើងមិនបានគិត មានតែព្រះបិតាមួយព្រះអង្គគត់ ដែលយល់ពីគម្រោងការណ៍នៃព្រះបុត្រាឮ។ ជាងពីរពាន់ឆ្នាំហើយ ដែលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ តែព្រះបន្ទូលនេះ កំពុងតែបន្តនិង មានអត្ថន័យរហូតដល់សព្វថ្ងៃ ។

គ្រីស្តបរិស័ទ ត្រូវយកចិត្តទុកដាក់ដោយត្រៀមខ្លួនយ៉ាងពិតប្រកដ គឺអធិដ្ឋាន ចូលរួមអភិបូជា ព្យាយាមស្តាប់ព្រះបន្ទូលព្រះអង្គ ព្រមទាំងយកព្រះបន្ទូលនោះ មកស្មឹងស្មាធិ៍រិះគិតពិចារណា។ គ្រីស្តបរិស័ទត្រូវមានសេចក្តីសង្ឃឹមថា មានតែព្រះអង្គមួយគត់ដែលជាព្រះសង្គ្រោះ ដែលនាំយើងឆ្ពោះទៅព្រះបិតា គឺព្រះអង្គជាស្ពានមេត្រីរវាងព្រះជាម្ចាស់និងមនុស្សលោក ។

ហេតុនេះចូរប្រុងប្រៀបខ្លួន ដោយមានសេចក្តីសង្ឃឹម និងមានចិត្តចេះរង់ចាំ។

**២២ វិច្ឆិកា៖ (លើកតម្កើងព្រះគ្រីស្តជាព្រះមហាក្សត្រពិភពលោក) យហ១៨,៣៣ខ-៣៧**

តាមរយៈអត្ថព្រះគម្ពីរ យ៉ូហាន ១៨, ៣៣-៣៧ ព្រះយេស៊ូបង្ហាញថា ព្រះអង្គជាព្រះមហាក្សត្រ តែមិនមែនតាមមនុស្សគិតទាល់តែសោះ។ ព្រះអង្គប្រកាសដូច្នេះ នៅចំពោះមុខមហាបូជាចារ្យដែលកាត់ទោសព្រះអង្គ។ ព្រះអង្គជាសាក្សី ដ៏ស្មោះត្រង់របស់ព្រះបិតា គឺធ្វើសាក្សីអំពីសេចក្តីស្រឡាញ់ តាមព្រះហឫទ័យព្រះបិតា។

ព្រះយេស៊ូ ជាសញ្ញាបញ្ជាក់ថាព្រះអង្គជាអ្នកបម្រើ ដោយមិនគិតពីឋានៈ ជាពិសេស ព្រះអង្គដាក់ខ្លួនបម្រើអ្នកក្រីក្រ អ្នកដែលសង្គមមិនរាប់រក ឬសង្គមបោះបង់ចោល មិនតែប៉ុណ្ណោះព្រះអង្គផ្សព្វផ្សាយធម៌ដល់មនុស្សលោក ឲ្យលើកលែងទោស ឱ្យគ្នាទៅវិញទៅមកព្រម-ទាំងរស់នៅតាមសេចក្តីពិត ដោយមានចិត្តស្មោះត្រង់។

ហេតុនេះ អ្នកណាធ្វើតាមព្រះបន្ទូលព្រះយេស៊ូ ឬចុះចូលក្រោមអំណាច និងផ្ញើជីវិតទាំងស្រុងលើព្រះអង្គ "អ្នកនោះកើតពីសេចក្តីពិត ហើយអ្នកនោះ នឹងស្តាប់សម្លេងព្រះអង្គ"។

**២៩ វិច្ឆិកា៖ (អាទិត្យទី១ក្នុងរដូវអបអរព្រះគ្រីស្តយាងមក)(ឆ្នាំ គ) លក២១,២៥-២៨.២៤-៣៦**

ដូចបងប្អូនធ្លាប់បានឮក្នុងព្រះគម្ពីរព្យាការីដានីអែល ៧,១៣ សុបិននិមិត្តអំពីបុត្រមនុស្ស ដែលយាងមកប្រ កបដោយសិរីរុងរឿងប្រសើរអស្ចារ្យ ដែលនាំឱ្យអស់អ្នក ដែលទន្ទឹងរង់ចាំមានសេចក្តីសេចក្តីសង្ឃឹម និងវិវរណៈ ១,៧ *"មើល! ព្រះអង្គយាងមក នៅកណ្តាលពពក មនុស្សទាំងអស់នឹងឃើញព្រះអង្គ"*។

តាមព្រះបន្ទូលព្រះយេស៊ូ គឺព្រះអង្គបានសន្យាថា ព្រះអង្គនឹងយាងមកវិញម្តងទៀត ដើម្បីវិនិច្ឆ័យមនុស្សលោកទាំងរស់ទាំងស្លាប់ ឱ្យគេមានសេចក្តីសង្ឃឹមថ្មី។ ព្រះអង្គនឹងរំដោះយើងរាល់គ្នា គឺព្រះអង្គរំដោះឱ្យរួចពីអំពើអាក្រក់ រួចពីបាបកម្ម និងទុក្ខទាំងឡាយ ។

ដូចគ្រីស្តបរិស័ទ នៅពេលដែលពួក-គេធ្វើជំហានទីមួយ គេសន្យាថាយកព្រះគ្រីស្តជាទីពឹង យកព្រះបន្ទូលជាទីពឹង និងយកព្រះសហគមន៍ជាទីពឹង ព្រមទាំងទទួលអគ្គសញ្ញាជ្រមុជទឹក ក្លាយជាមនុស្សថ្មី ដោយរួមរស់រួមស្លាប់ជា-មួយព្រះគ្រីស្ត គឺបំផ្លាស់ បំប្រែជីវិតរបស់យើងតាមលក្ខណៈថ្មី ដូចព្រះជាម្ចាស់ប្រែពិភពលោក ឱ្យមានលក្ខណៈថ្មីអញ្ចឹងដែរ។

## កំណាព្យ ក្នុងនាមកូនខ្មែរត្រូវអភិរក្សអក្សរសាស្ត្រខ្មែរ



*និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង សុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្នួល / JSC*

(បទពាក្យ ៧)

១- អក្សរសាស្ត្រខ្មែរថៃអក្ខរា
តួព្យញ្ជនៈស្រៈចំណាំ
ដែលបុត្រធីតារៀនចេះចាំ
បូកចែកដាក់ដាំលេខគុណគួរ ។

២- សម្តេចព្រះសង្ឃអង្គជួនណាត
សម្រាប់កូនខ្មែរថៃគិតគួរ
ចងក្រងក្បួនខ្នាតយ៉ាងគំរូ
សូមកុំផ្លាស់ប្តូរអត្ថន័យ។

៣- កកើតកំណើតកំណត់ខ្លួន
កុំប្រែក្រឡាស់ឲ្យផុតន័យ
ពាក្យកាព្យជាប់ជួនផ្ទួនសេចក្តី
បំប្លែងក្រឡៃឆ្នៃអក្ខរា ។

៤- សាសព្ទសម្លេងភ្លេងព្យញ្ជនៈ
តម្រួតព្យាង្គរាយបង្កើតការ
ប្រកបលើកដាក់តាមតម្រា
ឲ្យសមនឹងសារអក្ខរាមាន ។

៥- កុំថែមពាក្យថ្មីបំភ្លៃផ្លាស់
វប្បធម៌ប្រទេសគេរុករាន
បំបាត់ពាក្យចាស់ទាំងបំពាន
ចាប់យកជាស្ពានចម្លងតាម

៦- ពីមួយទៅមួយមិនព្រួយភ័យ
ផ្តើមតៗគ្នាចេះតែតាម
ទោះខុសសេចក្តីលិខិតស្នាម
ឥតមានហាមប្រាមកែតម្រូវ ។

៧- ពាក្យពេចន៍កាព្យខ្មែរជាភាសា
ដែលអស់កូនខ្មែរគ្រប់គ្រងត្រូវ
ក្នុងពង្សាវតារបិតថេរនៅ
អភិរក្សនូវអក្សរសាស្ត្រ ។

៨- ដែលជាដុំពេជ្រនៃវប្បធម៌
ប្រជាពលរដ្ឋទាំងក្មេងចាស់
ចែងចាំងបវរល្អក្រៃណាស់
ចេះចាំចងច្បាស់ក្នុងដួងចិត្ត ។

៩- លើកស្ទួយរក្សាអក្សរសិល្ប៍
កុំយកគំរូដែលមិនពិត
មានជនខូចខិលកែប្រឌិត
បន្លំទឹកចិត្តគិតថាល្អ។

១០- ពាក្យខ្មែរថៃខ្លួនសួនសំដី
ជួយអភិរក្សតួអក្សរ
ក្មេងចាស់ប្រុសស្រីមានឬក្រ
ឲ្យគង់វង្សល្អជាអង្វែង ។

# វិទ្យាស្ថានសន្តប៉ូល



## ថ្នាក់បរិញ្ញាបត្រ

វិស្វកម្មកម្មវិធី (Software Engineering)

- មហាវិទ្យាល័យព័ត៌មានវិទ្យា Faculty of Information Technology
  - វិស្វកម្មកម្មវិធី ( Software Engineering
  - ទូរគមនាគមន៍ និងបណ្តាញ ( Telecommunication and Network )
- ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស Department of English Literature
  - អប់រំភាសាអង់គ្លេស ( Teaching English as Foreign Language)
  - ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង ( English for Communication)
- ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍ Department of Tourism Management
- ដេប៉ាតឺម៉ង់កសិកម្មសាស្ត្រ Department of Agronomy
- ដេប៉ាតឺម៉ង់សង្គមកិច្ច Department of Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ Software Development
- គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ System and Network Administration
- បង្រៀនភាសាអង់គ្លេសជាភាសាទីពីរ Teaching English As Second Language
- សណ្ឋាគារ និងបដិសណ្ឋារកិច្ច Hotel and Hospitality
- ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ Fruit and Vegetable Crop Production
- ជំនាញកែច្នៃអាហារ Food Processing
- ប្រព័ន្ធកសិកម្មចម្រុះ Integrated Farming System
- ពេទ្យសត្វ Veterinary
- ថែទាំកុមារ Child care

## លក្ខខណ្ឌចូលរៀន

**សម្គាល់ ៖** រៀនបន្ថែម២ឆ្នាំនឹងទទួលបានសញ្ញាបត្របរិញ្ញាបត្រ

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើសម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២. បេក្ខជនធ្លាក់ថ្នាក់ទី១២ អាចចូលរៀនថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ

* ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៥

* ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៥

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002 / 032 639 0003 Email: spi.takeo@gmail.com | Web: www.spi.edu.kh

## សេចក្តីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ធ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែមអំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរ វត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144 ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ Email: martyrscambodia@gmail.com